ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ២៣៧ សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំ
# ស្តីពីការរៀបចំថវិកាកម្មវិធី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ០៦៨ សហវ.ប្រក ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ
- តាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ


វិលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ១.**_

ដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី ដូចមានខ្លឹមសារភ្ជាប់មកជាមួយប្រកាសនេះ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចធ្វើបច្ចុប្បន្នភាព និងកែសម្រួលគោលការណ៍ណែនាំនេះតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពនៃការរៀបចំថវិកាកម្មវិធី។

**ប្រការ២.**_

គ្រប់ក្រសួង ស្ថាប័ន ដែលចាប់ផ្តើមអនុវត្តថវិកាកម្មវិធី ត្រូវរៀបចំថវិកាដោយផ្អែកលើគោលការណ៍ណែនាំនេះ។

**ប្រការ៣.**_

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- គ្រប់ក្រសួង ស្ថាប័ន
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**នាយកដ្ឋានថវិកា**

# គោលការណ៍ណែនាំ
# ស្តីពី
# ការរៀបចំថវិកាកម្មវិធី

**ខែ កុម្ភៈ ឆ្នាំ ២០១១**

# មាតិកា

ទំព័រ


សទ្ទានុក្រម ........ 1

១. សេចក្តីផ្តើម ........ 4

១.១. គោលបំណងនៃគោលការណ៍ណែនាំ ........ 4

១.២. និយមន័យនៃថវិកាកម្មវិធី ........ 5

១.៣. អត្ថប្រយោជន៍នៃការអនុវត្តថវិកាកម្មវិធី ........ 5

១.៤. រចនាសម្ព័ន្ធនៃគោលការណ៍ណែនាំ ........ 6

២. ដំណើការនៃការរៀបចំថវិកាកម្មវិធី ........ 7

២.១. ការកសាងកម្មវិធី ........ 7

ជំហានទី ១ : ការផ្តើមចេញពីផែនការយុទ្ធសាស្ត្រថវិកា ........ 7

ជំហានទី ២ : វិធីសាស្ត្រក្នុងការបង្កើតកម្មវិធី និង រចនាសម្ព័ន្ធកម្មវិធី ........ 7

ជំហានទី ៣ : វិធីសាស្ត្រក្នុងការកំណត់ពីគោលបំណង (Objective) នៃកម្មវិធី និង អនុកម្មវិធី ........ 10

ជំហានទី ៤ : វិធីសាស្ត្រក្នុងការកំណត់ខ្សែចង្វាក់លទ្ធផល ........ 12

ជំហានទី ៥ : ពិនិត្យឡើងវិញ អំពីគុណភាពនៃការកសាងរចនាសម្ព័ន្ធកម្មវិធី ........ 19

២.២. ការកំណត់សូចនាករសមិទ្ធកម្ម ........ 20

ជំហានទី ៦ : វិធីសាស្ត្រក្នុងការកំណត់សូចនាករសមិទ្ធកម្ម ........ 20

២.៣ . ការគណនាតម្រូវការចំណាយសម្រាប់កម្មវិធី ........ 25

ជំហានទី ៧ : វិធីសាស្ត្រក្នុងការគណនាតម្រូវការចំណាយសម្រាប់កម្មវិធី ........ 25

២.៤. ការត្រួតពិនិត្យឡើងវិញលើថវិកាកម្មវិធីដែលបានកសាង ........ 33

ជំហានទី ៨ : វិធីសាស្ត្រក្នុងការត្រួតពិនិត្យឡើងវិញលើថវិកាកម្មវិធីដែលបានកសាង ........ 34

៣. ការពិនិត្យតាមដាន វាយតម្លៃការអនុវត្ត និង ធ្វើរបាយការណ៍ ........ 35

ជំហានទី ៩ : វិធីសាស្ត្រក្នុងការឆ្លើយតបទៅនឹងតម្រូវការសម្រាប់ពិនិត្យតាមដាន វាយតម្លៃ និង ធ្វើរបាយការណ៍ ........ 36

៤. ឧបសម្ព័ន្ធ ........ 38

ឧបសម្ព័ន្ធទី ១ ការកំណត់ធាតុចូល ចង្កោមសកម្មភាព លទ្ធផលក្នុងឆ្នាំ និង លទ្ធផលចុងក្រោយ : ........ 39

ឧបសម្ព័ន្ធទី ២ :ទម្រង់បែបបទនៃការរៀបចំសំណើថវិកាកម្មវិធី ........ 42

ឧបសម្ព័ន្ធទី ៣ :ទម្រង់សម្រាប់ការតាមដាន និង របាយការណ៍លើការអនុវត្តថវិកាកម្មវិធី ........ 47

# សន្ទានុក្រម

សន្ទានុក្រម ផ្តល់នូវនិយមន័យចំពោះពាក្យគន្លឹះៗ ដែលប្រើប្រាស់នៅក្នុងបរិបថនៃគោលការណ៍ណែនាំនេះ ។

| ពាក្យ | និយមន័យ |
|---|---|
| **ផែនការយុទ្ធសាស្ត្រថវិកា** (Budget Strategic Plan) | ជាផែនការថវិការយៈពេលមធ្យម (៣ ឆ្នាំ) ដែលក្រសួង ស្ថាប័ន និង មន្ទីរជំនាញរាជធានី ខេត្ត ត្រូវរៀបចំនៅក្នុងដំណាក់កាលទី ១ (មេសា-ឧសភា) នៃការរៀបចំថវិកាប្រចាំឆ្នាំនីមួយៗ ។ ផែនការនេះ រួមមានការឆ្លុះបញ្ចាំងទិសដៅគោលនយោបាយ ការកសាងកម្មវិធីយុទ្ធសាស្ត្រអាទិភាព និង ការកំណត់សូចនាករ ដើម្បីរួមចំណែកក្នុងការសម្រេចផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង គោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ។ ផែនការយុទ្ធសាស្ត្រថវិកា ទាមទារការកំណត់ធនធានទាំងចរន្ត និង មូលធនដែលត្រូវការ និង ប្រើប្រាស់សម្រាប់ឆ្នាំថវិកាកំពុងរៀបចំ និង ពីរឆ្នាំទៅមុខទៀត ដើម្បីសម្រេចបានតាមទិសដៅគោលនយោបាយ និង កម្មវិធី ឬ យុទ្ធសាស្ត្រអាទិភាពរបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញរាជធានី ខេត្ត ។ |
| **ចក្ខុវិស័យ** (Vision) | ជាទស្សនទានទូលំទូលាយមួយដែលបង្ហាញពីបំណងប្រាថ្នារយៈពេលវែង ។ |
| **ទិសដៅ** (Goal) | ជាការកំណត់ទិសមួយដ៏ជាក់លាក់ ដើម្បីសម្រេចបាននូវចក្ខុវិស័យ ។ ជារួម ទិសដៅមិនត្រូវបានធ្វើការផ្លាស់ប្តូរទេ នៅក្នុងរយៈពេលមធ្យម ។ |
| **គោលនយោបាយ** (Policy) | ជាឧបករណ៍ ឬ មធ្យោបាយ ដើម្បីឈានទៅសម្រេចទិសដៅ និង ចក្ខុវិស័យដែលបានកំណត់ ។ |
| **គោលបំណង** (Objective) | គឺជាការកំណត់ពីបំណង និង ពេលវេលាដែលអាចសម្រេចបានទិសដៅគោលនយោបាយ ដែលបានដាក់ចេញ ។ |
| **យុទ្ធសាស្ត្រ** (Strategy) | ជាវិធីសាស្ត្រក្នុងការអនុវត្ត ដើម្បីសម្រេចបាននូវទិសដៅគោលនយោបាយ និងគោលបំណងដែលបានដាក់ចេញ ។ |
| **គោលដៅ** (Target) | ជាគោលជាក់លាក់មួយបង្ហាញពីបរិមាណ ឬ គុណភាពដែលអាចវាស់វែងបាន និង អាចសម្រេចបានទៅតាមការកំណត់ពេលវេលាច្បាស់លាស់ ។ |
| **កម្មវិធី** (Program) | ជាវិធីសាស្ត្រក្នុងការអនុវត្ត ដើម្បីសម្រេចបាននូវគោលបំណងគោលនយោបាយ ។ កម្មវិធីក៏ជាមូលដ្ឋានសម្រាប់បង្កើតអនុកម្មវិធីផងដែរ ។ |

**អនុកម្មវិធី** (Sub-Program) — ជាបណ្តុំនៃចង្កោមសកម្មភាពដែលបម្រើឱ្យគោលបំណងនៃកម្មវិធី ។

**ចង្កោមសកម្មភាព** (Activity) — ជាបណ្តុំសកម្មភាពដែលបម្រើឱ្យគោលបំណងនៃអនុកម្មវិធី ។

**ធាតុចូល** (Input) — ជាធនធានហិរញ្ញវត្ថុ និង មិនមែនហិរញ្ញវត្ថុដែលត្រូវការចាំបាច់ ដើម្បីអនុវត្តសកម្មភាព ។ និយាយម្យ៉ាងទៀត ធាតុចូលជាធនធានចាំបាច់សម្រាប់បង្កើតលទ្ធផល ។

**លទ្ធផលក្នុងឆ្នាំ** (Output) — ជាលទ្ធផល ដែលអាចវាស់បានក្នុងឆ្នាំ ក្រោយពីការអនុវត្តកម្មវិធី អនុកម្មវិធី ឬ ចង្កោមសកម្មភាព ។

**លទ្ធផលចុងក្រោយ** (Outcome) — ជាលទ្ធផលសម្រេចបានពីមួយឆ្នាំទៅមួយឆ្នាំ ក្រោយពីការអនុវត្តបានពេញលេញនូវអនុកម្មវិធី និង កម្មវិធី ក្នុងរយៈពេលកំណត់មួយ ។

**ថ្លៃធាតុចូល** (Input Costs) — គឺជាការគណនាតម្រូវការចំណាយធាតុចូលដែលរួមទាំងថ្លៃចំណាយមូលធន និង ថ្លៃចំណាយចរន្ត ។

**ថ្លៃចំណាយមូលធន (Capital Costs)**

ថ្លៃចំណាយមូលធនសំដៅលើចំណាយ ដើម្បីទទួលបាននូវអចលកម្ម (ចលនទ្រព្យ និង អចលនទ្រព្យ) ។

**ថ្លៃចំណាយចរន្ត (Recurrent Costs)**

ជាចំណាយប្រតិបត្តិការ ក្រៅពីចំណាយអចលកម្មដែលត្រូវប្រើប្រាស់ជាប្រចាំ ដូចជាប្រាក់បៀវត្ស ឬ ចំណាយសម្រាប់ដំណើរការរដ្ឋបាលផ្សេងៗទៀត ។

**សូចនាករសមិទ្ធកម្ម** (Performance Indicator) — ជារង្វាស់លើលទ្ធផលដែលសម្រេចបាន ។

**សូចនាករធាតុចូល (Input Indicator)**

ជារង្វាស់តម្រូវការធនធានសម្រាប់អនុវត្តកម្មវិធី ។

**សូចនាករលទ្ធផលក្នុងឆ្នាំ (Output Indicator)**

ជារង្វាស់លទ្ធផលក្នុងឆ្នាំ លើការអនុវត្តចង្កោមសកម្មភាព អនុកម្មវិធី ឬ កម្មវិធី ធៀបទៅនឹងគោលដៅដែលបានកំណត់ ដើម្បីបញ្ជាក់ពីប្រសិទ្ធភាពថវិកា ។

**សូចនាករលទ្ធផលចុងក្រោយ (Outcome Indicator)**

ជារង្វាស់ភាពស័ក្តិសិទ្ធិនៃលទ្ធផលចុងក្រោយ ផ្អែកលើមូលដ្ឋាននៃលទ្ធផលក្នុងឆ្នាំ ដែលសម្រេចបាន ។ ជារួម សូចនាករចុងក្រោយវាស់វែងពីបរិមាណ និង គុណភាព លទ្ធផល ព្រមទាំងប្រសិទ្ធភាពនៃកម្មវិធី និង អនុកម្មវិធី ។

**សូចនាករចង្កោមសកម្មភាព (Activity Indicator)**

ជារង្វាស់លទ្ធផលនៃដំណើរការអនុវត្តចង្កោមសកម្មភាព ធៀបទៅនឹងពេលវេលា និង ធនធាន ដែលបានកំណត់ ។

**ប្រសិទ្ធភាព** (Efficiency)
ការប្រៀបធៀបរវាងលទ្ធផលក្នុងឆ្នាំដែលសម្រេចបានទៅនឹងធាតុចូល ដែលបានប្រើប្រាស់ ។ ជារួម ប្រសិទ្ធភាពគឺជាអនុបាត(Ratio) នៃធាតុចូល និង លទ្ធផលទទួលបាន ។ ការវាស់វែងប្រសិទ្ធភាពដែលយើងប្រើប្រាស់ជាទូទៅ គឺនិយាយពីប្រសិទ្ធភាពចំណាយដែលត្រូវបានប្រើប្រាស់សម្រាប់បង្កើតលទ្ធផលក្នុងឆ្នាំ និង លទ្ធផលចុងក្រោយ ។

**ភាពស័ក្តិសិទ្ធិ** (Effectiveness)
ការប្រៀបធៀបលទ្ធផលក្នុងឆ្នាំ និង លទ្ធផលចុងក្រោយទៅនឹងគោលបំណងគោលនយោបាយដែលបានដាក់ចេញ ។

**ខ្សែចង្វាក់លទ្ធផល** (The Results Chain)
ការផ្សារភ្ជាប់ និង ទំនាក់ទំនងរវាងចង្កោមសកម្មភាព ធាតុចូល លទ្ធផលក្នុងឆ្នាំ និង លទ្ធផលចុងក្រោយរបស់កម្មវិធីនីមួយៗ ។

# ១. សេចក្តីផ្តើម

ស្របតាមកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ (២០០៥-២០១៥) ថវិកាកម្មវិធី ត្រូវបានដាក់ឱ្យអនុវត្តសាកល្បងចាប់ពីឆ្នាំ ២០០៧ នៅក្នុងក្រសួងចំនួន ៧ ដែលរួមមាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ, ក្រសួងអប់រំ យុវជន និង កីឡា, ក្រសួងសុខាភិបាល, ក្រសួងយុត្តិធម៌, ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់, ក្រសួងអភិវឌ្ឍន៍ជនបទ, និង ក្រសួងកិច្ចការនារី ។ ក្រោយមកនៅឆ្នាំ ២០០៨ ការសាកល្បង ត្រូវបានពង្រីកវិសាលភាពដល់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ។ ការដាក់ឱ្យអនុវត្តថវិកាកម្មវិធី នឹងត្រូវពង្រីកវិសាលភាពទៅដល់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្តជាជំហានៗ ដើម្បីឈានទៅអនុវត្តឱ្យបានពេញលេញនៅក្នុងដំណាក់កាលទី ៣ នៃកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ។

ដើម្បីបម្រើការសាកល្បងថវិកាកម្មវិធី នាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានខិតខំកសាងគោលការណ៍ណែនាំនេះឡើង ដោយផ្អែកលើការសិក្សាស្រាវជ្រាវរបស់នាយកដ្ឋានថវិកា បទពិសោធន៍នៃការដាក់ឱ្យអនុវត្តសាកល្បង និង បទពិសោធន៍ ដែលទទួលពីទស្សនកិច្ចសិក្សានៅប្រទេសអូស្ត្រាលី, ប្រទេសថៃ ប្រទេសសិង្ហបុរី និង ប្រទេសនូវែលហ្សេឡង់ ផងដែរ ។

## ១.១. គោលបំណងនៃគោលការណ៍ណែនាំ

**គោលការណ៍ណែនាំនេះ** ជាមគ្គុទេសសម្រាប់ជួយណែនាំ អំពីវិធីសាស្ត្រនៃការរៀបចំថវិកាកម្មវិធីដល់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្តរៀងៗខ្លួនដែលបាន និង កំពុងអនុវត្តសាកល្បង និង បន្តពង្រីកទៅក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្តផ្សេងទៀត ។ ទន្ទឹមនឹងនេះ កម្មវិធីដែលបានកសាងឡើង ត្រូវធានាថា គឺជាយុទ្ធសាស្ត្រអាទិភាព ឈានទៅសម្រេចបានគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្ត ក៏ដូចជាគោលនយោបាយវិស័យទាំងមូល ។

**គោលការណ៍ណែនាំនេះ** ជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ដើម្បីកែលម្អ និង ធានាការអនុវត្តថវិកាកម្មវិធីឱ្យមានភាពស័ក្តិសិទ្ធិ ។ យើងទទួលស្គាល់ថា ការដាក់ឱ្យអនុវត្តថវិកាកម្មវិធី គឺជាដំណើរការមួយ ដែលតម្រូវឱ្យមានការកែលម្អជាប្រចាំ ។ នៅក្នុងបរិបទនេះ នាយកដ្ឋានថវិកានឹងបន្តធ្វើការកែលម្អគោលការណ៍ណែនាំនេះពីមួយឆ្នាំទៅមួយឆ្នាំ ទៅតាមបទពិសោធន៍នៃការអនុវត្តជាក់ស្តែង និង បទពិសោធន៍នៃបណ្តាប្រទេសដទៃនៅក្នុងតំបន់ផងដែរ ដើម្បីឱ្យគោលការណ៍ណែនាំនេះកាន់តែមានសុក្រឹតភាព ពិសេសធានាបាននូវការអនុវត្តថវិកាកម្មវិធីមួយដែលសមស្របសម្រាប់កម្ពុជា ។

ដើម្បីដោះស្រាយមន្ទិលបឋមដែលអ្នកអានអាចមាន នៅពេលចាប់ផ្តើមអានគោលការណ៍ណែនាំនេះ យើងសូមផ្តល់ជូននូវនិយមន័យនៃ **"ថវិកាកម្មវិធី"** ពីដើមដំបូងនៃគោលការណ៍ណែនាំនេះតែម្តង ។ ចំពោះខ្លឹមសារស៊ីជម្រៅ និង លំអិតនឹងផ្តល់ជូនជាបន្តបន្ទាប់ ។

## ១.២. និយមន័យនៃថវិកាកម្មវិធី

ថវិកាកម្មវិធី គឺជាការរៀបចំថវិកាដោយផ្អែកលើកម្មវិធីច្បាស់លាស់ ដើម្បីឈានទៅសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្ត ស្របតាមគោលនយោបាយដែលមានចែងនៅក្នុងវិស័យនីមួយៗ ។ ទន្ទឹមនឹងនេះ ថវិកាកម្មវិធី ត្រូវមានសូចនាករសមិទ្ធកម្មសម្រាប់ជាយន្តការតាមដាន ដើម្បីវាស់វែង និង ធ្វើរបាយការណ៍លទ្ធផលក្នុងឆ្នាំ និង លទ្ធផលចុងក្រោយទៅតាមអនុកម្មវិធី និង កម្មវិធីនីមួយៗ ។ ថវិកាកម្មវិធី ត្រូវកំណត់ឱ្យបានច្បាស់នូវថ្លៃធាតុចូល ដែលរួមមានចំណាយចរន្ត និង ចំណាយមូលធនចាំបាច់សម្រាប់ការអនុវត្តចង្កោមសកម្មភាព អនុកម្មវិធី និង កម្មវិធី ។

## ១.៣. អត្ថប្រយោជន៍នៃការអនុវត្តថវិកាកម្មវិធី

ថវិកាកម្មវិធី នឹងជួយពង្រឹងដល់ការផ្សារភ្ជាប់រវាងថវិកា និង គោលនយោបាយតាមវិស័យ និង គោលនយោបាយរបស់រាជរដ្ឋាភិបាល ព្រោះថាថវិកាជាឧបករណ៍គោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលរួមមានគោលនយោបាយចំណូល និង គោលនយោបាយចំណាយ ។ ការផ្សារភ្ជាប់នេះ នឹងជំរុញការយកចិត្តទុកដាក់ទៅលើការបញ្ជាក់ពីមូលហេតុនៃតម្រូវការចំណាយ និង គណនេយ្យភាពចំពោះលទ្ធផលដែលត្រូវសម្រេចបាន ។

ថវិកាកម្មវិធី នឹងផ្តល់ជាមធ្យោបាយមួយផងដែរ ដើម្បីធ្វើការពិនិត្យឡើងវិញអំពីការបែងចែកធនធាន ដែលបានរៀបចំនៅក្នុងដំណាក់កាលនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ជាពិសេសផ្តល់លទ្ធភាពពិនិត្យ និង ថ្លឹងថ្លែងឡើងវិញ រវាងអាទិភាពនៃគោលនយោបាយចាស់ និង គោលនយោបាយថ្មីនៅពេលចាប់ផ្តើមរៀបចំថវិកាឆ្នាំបន្ទាប់ ។

ផ្ទុយទៅវិញ ការរៀបចំថវិកាតាមមាតិកាគឺជាការធ្វើថវិកា ដោយផ្តោតតែលើមូលដ្ឋានតម្រូវការធាតុចូលទៅតាមប្រភេទ ជំពូក គណនី និង អនុគណនី ដែលមិនអាចឱ្យយើងសម្រេចបានគោលបំណងខាងលើនេះទេ ពីព្រោះការរៀបចំថវិកាតាមមាតិកា អនុញ្ញាតឱ្យយើងកត់ត្រាបានតែមុខសញ្ញាចំណាយតាមបែបសេដ្ឋកិច្ច ដែលបម្រើតែគោលដៅរបាយការណ៍គណនេយ្យប៉ុណ្ណោះ ។ ជារួម ថវិកាតាមមាតិកានេះ មិនបានជួយផ្សារភ្ជាប់ទំហំចំណាយលើធាតុចូលដែលបានផ្តល់ទៅនឹងលទ្ធផលក្នុងឆ្នាំ និង លទ្ធផលចុងក្រោយដែលក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្តរំពឹងទុក ។ ជាលទ្ធផល ការអនុវត្តថវិកាតាមមាតិកាបង្កើតជាផ្នត់គំនិតមួយឱ្យក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្ត ទាមទារកំណើនថវិកាប្រចាំឆ្នាំ ដោយផ្អែកតែទៅលើថវិកាឆ្នាំកន្លងមក ដោយមិនបានយកចិត្តទុកដាក់ដល់លទ្ធផលរំពឹងទុកឡើយ ។

ការអនុវត្តថវិកាកម្មវិធី នឹងបង្កើតឡើងនូវមូលដ្ឋានគ្រឹះសម្រាប់កែលម្អនូវ ៖

- ផែនការថវិកា តាមរយៈការភ្ជាប់រវាងថវិកា និង គោលដៅគោលនយោបាយ

- លទ្ធផលចុងក្រោយដែលក្រសួង ស្ថាប័ន មន្ទីរជំនាញ រាជធានី ខេត្ត សម្រេចបានតាមកម្មវិធីនីមួយៗ ឆ្លើយតបទៅនឹងថវិកាដែលបានចំណាយ ។ ជាលទ្ធផល ការផ្សារភ្ជាប់រវាងគោលនយោបាយ និង ថវិកា នឹងត្រូវបានពង្រឹងស្របតាមអាទិភាពនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ការអនុវត្តថវិកាដើម្បីជួយពង្រឹង និង បង្កើតឲ្យមានបន្ទាត់គណនេយ្យភាព
- ការតាមដាន វាយតម្លៃ និង ការធ្វើរបាយការណ៍លទ្ធផលនៃការអនុវត្តថវិកា ។

## ១.៤. រចនាសម្ព័ន្ធនៃគោលការណ៍ណែនាំ

គោលការណ៍ណែនាំនេះ ត្រូវបានចែកចេញជា ៤ ផ្នែក រួមមានសេចក្តីផ្តើម ដំណើរការនៃការរៀបចំថវិកាកម្មវិធី និង ការពិនិត្យតាមដានវាយតម្លៃការអនុវត្ត និង ការធ្វើរបាយការណ៍ ព្រមទាំងឧបសម្ព័ន្ធមួយចំនួន រួមមាន (ទី ១) ការកំណត់ធាតុចូល, ចង្កោមសកម្មភាព, លទ្ធផលក្នុងឆ្នាំ, លទ្ធផលចុងក្រោយ (ទី ២) ទម្រង់បែបបទនៃការរៀបចំសំណើសុំថវិកាកម្មវិធី (ទី ៣) ទម្រង់សម្រាប់ការតាមដាន និង របាយការណ៍លើការអនុវត្តថវិកាកម្មវិធី ។

ការអធិប្បាយអំពីដំណើរការនៃការរៀបចំថវិកាកម្មវិធី ត្រូវបានបែងចែកទៅតាមផ្នែក ដូចតទៅ ៖

**ផ្នែកទី ១ : ការកសាងកម្មវិធី**

ផ្តល់ការណែនាំពីវិធីសាស្ត្រក្នុងការបង្កើតរចនាសម្ព័ន្ធកម្មវិធី និង អនុកម្មវិធី និង ផ្តល់ការណែនាំពីរបៀបកំណត់ និង ឯកភាពទៅលើគោលបំណង លទ្ធផលចុងក្រោយ លទ្ធផលក្នុងឆ្នាំ និង ចង្កោមសកម្មភាព ។

**ផ្នែកទី ២ : ការកំណត់សូចនាករសមិទ្ធកម្ម**

ផ្តល់ការណែនាំពីប្រភេទនៃសូចនាករសមិទ្ធកម្មដែលត្រូវជ្រើសរើស ដើម្បីតាមដានវឌ្ឍនភាព និង សមិទ្ធផលនៃកម្មវិធី និង ផ្តល់បញ្ជីសំណួរ ដើម្បីវាយតម្លៃថាតើសូចនាករដែលជ្រើសរើស មានភាពសមស្របដែរឬទេ ។

**ផ្នែកទី ៣ : ការគណនាតម្រូវការចំណាយសម្រាប់កម្មវិធី**

ផ្តល់ការណែនាំពីវិធីសាស្ត្រក្នុងការគណនាតម្រូវការចំណាយ សម្រាប់ធាតុចូលនៃកម្មវិធី និង ផ្តល់បញ្ជីសំណួរ ដើម្បីវាយតម្លៃថា តើការកំណត់ថ្លៃសម្រាប់កម្មវិធីមានភាពសមស្របដែរឬទេ ។

**ផ្នែកទី ៤ : ការត្រួតពិនិត្យឡើងវិញលើថវិកាកម្មវិធី ដែលបានកសាង**

ផ្តល់ការណែនាំ អំពីការត្រួតពិនិត្យឡើងវិញលើថវិកាកម្មវិធីដែលបានកសាង និង កំណត់ឲ្យបានជាក់លាក់ពីតម្រូវការថ្លៃធាតុចូល ដើម្បីធានាថាថវិកាកម្មវិធីដែលបានកសាង អាចសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្ត ។

# ២. ដំណើរការនៃការរៀបចំថវិកាកម្មវិធី

## ២.១. ការកសាងកម្មវិធី

ផ្នែកនេះ ផ្តល់នូវវិធីសាស្ត្រសម្រាប់ការកសាងឡើងនូវកម្មវិធី ដោយផ្អែកលើផែនការយុទ្ធសាស្ត្រថវិកា (Budget Strategic Plan – BSP) ដែលក្រុមការងារថវិការបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្ត បានរៀបចំឡើងនៅក្នុងដំណាក់កាលទី ១ នៃការរៀបចំថវិកាទៅតាមជំហានៗជាបន្តបន្ទាប់ ដូចខាងក្រោម ៖

### ជំហានទី ១ : ការផ្តើមចេញពីផែនការយុទ្ធសាស្ត្រថវិកា

ក្រុមការងារថវិកា ត្រូវប្រជុំពិភាក្សាឡើងវិញលើផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្ត ដែលបានដាក់ចេញ ដោយពិនិត្យទៅលើគោលបំណងគោលនយោបាយដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន ដើម្បីកំណត់ថា ត្រូវមានកម្មវិធីអ្វីខ្លះសម្រាប់ជាយុទ្ធសាស្ត្រក្នុងការឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

ក្រុមការងារថវិកា ត្រូវកំណត់ថា គោលបំណងគោលនយោបាយមួយ អាចសម្រេចបានតាមរយៈកម្មវិធីមួយ ឬ ពីរយ៉ាងច្រើន ។ គួរកត់សម្គាល់ថា មិនមែនកម្មវិធីមួយទៅសម្រេចនូវគោលបំណងគោលនយោបាយច្រើននោះទេ ។ បើក្រុមការងារ ពិចារណាឃើញបែបនេះ ក្រុមការងារត្រូវពិនិត្យគោលបំណងគោលនយោបាយរបស់ក្រសួងឡើងវិញ ព្រោះថាគោលបំណងគោលនយោបាយនោះ អាចមិនមែនជាគោលនយោបាយធំៗ និងទូលំទូលាយ តែជាគោលបំណងតូចៗដែលអាចប្រមូលផ្តុំឡើងវិញឲ្យទៅជាគោលបំណងធំៗ ។ ក្រុមការងារក៏ត្រូវពិនិត្យឡើងវិញដែរ អ្វីទៅហៅថា**ចក្ខុវិស័យ, គោលបំណងគោលនយោបាយ, បេសកកម្ម, គោលដៅ និង យុទ្ធសាស្ត្រ** ។ បញ្ហានេះ គួរពិនិត្យនិយមន័យនៃវាក្យស័ព្ទទាំងអស់នេះឡើងវិញ នៅក្នុងសន្ទានុក្រមដែលបានពន្យល់ពីខាងដើម ។

ជារួម ការរៀបចំបង្កើតកម្មវិធី ត្រូវចាប់ផ្តើមពីគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ។

### ជំហានទី ២ : វិធីសាស្ត្រក្នុងការបង្កើតកម្មវិធី និង រចនាសម្ព័ន្ធកម្មវិធី

**(ជំហានទី ២ នេះ ផ្តល់នូវគំនិត និង សេចក្តីពន្យល់ ដើម្បីបំពេញព័ត៌មាននៅក្នុងជួរឈរទី ១ នៃតារាងឧបសម្ព័ន្ធទី ២.១, ២.២ ដូចមានជូនភ្ជាប់មកជាមួយ)**

នៅពេលដែលផែនការយុទ្ធសាស្ត្រថវិកាត្រូវបានរៀបចំរួចរាល់ហើយ ជំហានបន្ទាប់គឺត្រូវបង្កើត និងកំណត់ចំនួនកម្មវិធី និង រចនាសម្ព័ន្ធកម្មវិធី ។ ការងារនេះ ត្រូវដឹកនាំ និង រៀបចំដោយក្រុមការងារថវិកា ។ ដើម្បីឲ្យការរៀបចំ និង ការអនុវត្តកម្មវិធី អាចប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព ក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្ត ត្រូវកំណត់ឲ្យមានអ្នកទទួលខុសត្រូវចំពោះកម្មវិធី និង អនុកម្មវិធី ។

តើរចនាសម្ព័ន្ធកម្មវិធីត្រូវកសាងតាមវិធីណា?

| | គោលការណ៍ | អនុសាសន៍ |
|---|---|---|
| កម្មវិធី | • កម្មវិធីមួយ ត្រូវមានគោលបំណងច្បាស់លាស់មួយ ។<br>• កម្មវិធីមួយ ត្រូវមានយ៉ាងហោចណាស់សូចនាករលទ្ធផលចុងក្រោយមួយ និង លទ្ធផលក្នុងឆ្នាំមួយចំនួន ។<br>• ក្រសួងគួរមានកម្មវិធីច្រើនបំផុត ប្រាំ ។ | កម្មវិធី គួរទទួលខុសត្រូវដោយមន្ត្រីជាន់ខ្ពស់មួយរូបដែលមានឋានៈ ចាប់ពីអគ្គលេខាធិការរង ឬ អគ្គនាយករងឡើងទៅ ស្របតាមរចនាសម្ព័ន្ធជាក់ស្តែងរបស់ក្រសួង ស្ថាប័ននីមួយៗ ។ |
| អនុកម្មវិធី | • ចំនួនអនុកម្មវិធី គួរសមស្របទៅនឹងតម្រូវការជាក់ស្តែងរបស់កម្មវិធី ជាពិសេស ដើម្បីឆ្លើយតបទៅនឹងគោលបំណងរបស់កម្មវិធី ។<br>• អនុកម្មវិធីមួយ គួរមានសូចនាករលទ្ធផលក្នុងឆ្នាំមួយ ឬ ច្រើន ដើម្បីរួមវិភាគទាន សម្រេចបានគោលបំណងរួម និង លទ្ធផលចុងក្រោយនៃកម្មវិធីមួយ ។ | អនុកម្មវិធី គួរទទួលខុសត្រូវដោយប្រធាននាយកដ្ឋាន ស្របតាមរចនាសម្ព័ន្ធ ជាក់ស្តែងរបស់ក្រសួង ស្ថាប័ននីមួយៗ ។ |
| ចង្កោមសកម្មភាព | • ចង្កោមសកម្មភាព អាចមានចំនួនច្រើន នៅក្នុងនាយកដ្ឋានមួយ ក៏ប៉ុន្តែ ត្រូវបែងចែកការទទួលខុសត្រូវឲ្យបានច្បាស់លាស់ទៅតាមរចនាសម្ព័ន្ធរបស់នាយកដ្ឋាន ។<br>• ចង្កោមសកម្មភាពមួយ ត្រូវមានសូចនាករលទ្ធផលក្នុងឆ្នាំមួយយ៉ាងតិច សម្រាប់វាស់វែងការអនុវត្តប្រចាំឆ្នាំ ។ | ចង្កោមសកម្មភាព គួរទទួលខុសត្រូវដោយអនុប្រធាននាយកដ្ឋាន ប្រធានមន្ទីររាជធានី ខេត្ត ឬ ប្រធានការិយាល័យ (រដ្ឋបាលកណ្តាល) ស្របតាមរចនាសម្ព័ន្ធជាក់ស្តែងរបស់ក្រសួង ស្ថាប័ននីមួយៗ ។ |

អនុវត្តតាមគោលការណ៍ខាងលើ ក្រុមការងារថវិកានឹងសម្រេចបាននូវការបង្កើតកម្មវិធី និង រចនាសម្ព័ន្ធកម្មវិធី ដែលមានទំនាក់ទំនងទៅនឹងផែនការយុទ្ធសាស្ត្រថវិកា និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដូចមានបង្ហាញក្នុងតារាងទី ១ ខាងក្រោមនេះ ៖

**តារាងទី ១ : ទំនាក់ទំនងរវាងគោលនយោបាយ និង រចនាសម្ព័ន្ធកម្មវិធី**




ដើម្បីជួយជាគំនិតដល់ការបង្កើតរចនាសម្ព័ន្ធកម្មវិធីជាក់ស្តែង ក្រុមការងារថវិកាអាចពិនិត្យលើឧទាហរណ៍ នៃទំនាក់ទំនងរវាងកម្មវិធី និង អនុកម្មវិធីរបស់វិស័យមួយចំនួន ដូចខាងក្រោម ៖

**ឧទាហរណ៍ទី ១** : គោលបំណងគោលនយោបាយ : ការបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាយុត្តិធម៌ ប្រកបដោយសច្ចភាព ស្មើភាព និង តម្លាភាព ។

| **កម្មវិធី** | **អនុកម្មវិធី** |
|---|---|
| ១. ពង្រឹងសេវាយុត្តិធម៌ | ១.១. រៀបចំច្បាប់ |
| | ១.២. ផ្សព្វផ្សាយច្បាប់ |
| | ១.៣. សេវាតាមដាន និង អធិការកិច្ច |
| | ១.៤. ការកសាងសមត្ថភាព |

**ឧទាហរណ៍ទី ២** : គោលបំណងគោលនយោបាយ : ការកាត់បន្ថយអត្រាស្លាប់របស់មាតា ទារក និង កុមារ ។

| **កម្មវិធី** | **អនុកម្មវិធី** |
|---|---|
| ១. កម្មវិធីសុខភាពបន្តពូជ មាតា ទារក និង កុមារ | ១.១. លើកកំពស់ស្ថានភាពអាហារូបត្ថម្ភរបស់មាតា និង ទារក<br>១.២. លើកកំពស់លទ្ធភាពមកទទួលយកព័ត៌មាន និង សេវាសុខភាពបន្តពូជ មានគុណភាព<br>១.៣. លើកកំពស់លទ្ធភាពមកទទួលយកសេវាសារវន្ត សម្រាប់មាតា និង ទារក និង ការប្រព្រឹត្តិ ការថែទាំសុខភាព តាមគ្រួសារបាន ល្អប្រសើរ<br>១.៤. ធានានូវលទ្ធភាពមកទទួលយកសេវាសុខភាពសារវន្តសម្រាប់ កុមារ និង ការប្រព្រឹត្តិការថែទាំសុខភាពតាមគ្រួសារបានល្អប្រសើរ |

**ឧទាហរណ៍ទី ៣** : គោលបំណងគោលនយោបាយ: លើកកំពស់ការកែលម្អគុណភាព និង ប្រសិទ្ធភាពសេវាអប់រំ នៅគ្រប់កម្រិត ។

| **កម្មវិធី** | **អនុកម្មវិធី** |
|---|---|
| ១. ការអភិវឌ្ឍន៍អប់រំចំណេះទូទៅ និង ការអប់រំក្រៅប្រព័ន្ធ | ១.១. ការពង្រីកការអប់រំកុមារតូច<br>១.២. ការពង្រឹងគុណភាព និង ប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា<br>១.៣. ការពង្រឹងគុណភាព និង ប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា<br>១.៤. ការចូលរៀនប្រកបដោយសមធម៌ និង ការផ្តល់អាហារូបករណ៍ដល់ សិស្សក្រីក្រជួបការលំបាក<br>១.៥. ពង្រីកការអប់រំក្រៅប្រព័ន្ធ |

## ជំហានទី ៣ : វិធីសាស្ត្រក្នុងការកំណត់ពីគោលបំណង (Objective) នៃកម្មវិធី និង អនុកម្មវិធី

**(ជំហានទី ៣ នេះផ្តល់នូវគំនិត និង សេចក្តីពន្យល់ ដើម្បីបំពេញព័ត៌មាននៅក្នុងតារាងឧបសម្ព័ន្ធទី ២.១ ជួរឈរទី ៣ និងទី ៤ ដូចមានជូនភ្ជាប់មកជាមួយ)**

ការកសាងរចនាសម្ព័ន្ធកម្មវិធី គឺជាដំណើរការដែលត្រូវពិនិត្យសារចុះសារឡើង ដើម្បីធានាភាពត្រឹមត្រូវនៃកម្មវិធីដែលបានបង្កើត ជាពិសេស ធានាថាគោលបំណងនៃកម្មវិធីនីមួយៗ ឆ្លើយតបទៅនឹងគោលបំណងគោលនយោបាយ ដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ។ ក្នុងន័យនេះ ការបង្កើតកម្មវិធីនៅក្នុងជំហានទី ២ និង ការកំណត់ពីគោលបំណងនៃកម្មវិធី នៅក្នុងជំហានទី ៣ នេះ ស្ទើរតែកើតឡើងព្រមគ្នា ព្រោះថានៅពេលយើងកំណត់ឈ្មោះកម្មវិធី គឺយើងទាញចេញពីខ្លឹមសារ ឬ ពាក្យគន្លឹះនៃគោលបំណងគោលនយោបាយ ទន្ទឹមគ្នានេះ យើងក៏ត្រូវកំណត់ពីគោលបំណងនៃកម្មវិធីផងដែរ ដើម្បីធានាថាគោលបំណងនោះ សំដៅសម្រេចបានគោលបំណងគោលនយោបាយ ។

យើងត្រូវធ្វើការកត់សម្គាល់ថា កម្មវិធីត្រូវមានគោលបំណងមួយច្បាស់លាស់ ហើយអនុកម្មវិធីក៏ត្រូវមានគោលបំណងមួយដែរ ដើម្បីគាំទ្រដល់ការសម្រេចបាននូវគោលបំណងរួមនៃកម្មវិធីមួយ ។

មានវិធីជាច្រើន ដើម្បីបង្កើតគោលបំណងនៃកម្មវិធី ហើយក្រសួងនីមួយៗអាចប្រើប្រាស់ដំណើរការណាមួយដែលសមស្របតាមស្ថានភាពរបស់ខ្លួនដើម្បីបង្កើតគោលបំណង ។ សិល្បៈនៃការកំណត់គោលបំណង គឺផ្តើមចេញពីការពិនិត្យទៅលើបញ្ហាប្រឈមដែលត្រូវដោះស្រាយ ទន្ទឹមនោះ យើងក៏ត្រូវយកចិត្តទុកដាក់ផងដែរថាគោលបំណងនោះ មានទិសដៅ និង គោលដៅដែលអាចសម្រេចបាន ។ គោលបំណង ដែលសម្រេចបានត្រឹមត្រូវ គឺត្រូវស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់មន្ត្រីនៅក្នុងក្រសួងអាចអនុវត្តបាន ។ ការធ្វើដូចនេះ មិនត្រឹមតែអាចឱ្យយើងទទួលបាននូវការកែលម្អកម្មវិធី និង ការផ្តល់សេវាប៉ុណ្ណោះទេ ប៉ុន្តែវាក៏អាចជួយឱ្យមានទំនុកចិត្តថាកិច្ចការដែលត្រូវបំពេញអាចសម្រេចបានល្អ ។ ផ្ទុយទៅវិញ កម្មវិធីដែលមិនអាចអនុវត្តបាន ធ្វើឱ្យមន្ត្រីក្រសួងមានការបាក់ទឹកចិត្ត ។

**ឧទាហរណ៍ទី ៤** : រចនាសម្ព័ន្ធកម្មវិធី និង អនុកម្មវិធី

ឈ្មោះកម្មវិធី : ការកែលម្អសេវាការពារជនងាយរងគ្រោះ

គោលបំណងកម្មវិធី : បង្កើនប្រសិទ្ធភាពនៃសេវាការពារសុវត្ថិភាពជូនកុមារ ស្ត្រីងាយរងគ្រោះ, ជនចាស់ជរា និង ជនបាត់បង់សមត្ថភាពពលកម្ម

| **ទទួលយកបាន** | **មិនអាចទទួលយកបាន** |
|---|---|
| អនុកម្មវិធីទី ១ កែលម្អសេវាការពារកុមារ និង ស្ត្រីងាយរងគ្រោះ | អនុកម្មវិធីទី ១ ដំណើរការនៃការប្តឹង |
| គោលបំណង : បង្កើនប្រសិទ្ធភាពការពារកុមារ និង ស្ត្រីងាយរងគ្រោះ | គោលបំណង : ទទួលពាក្យបណ្តឹង និងចាត់ចែងភ្នាក់ងារ ឱ្យស៊ើបអង្កេតលើពាក្យបណ្តឹងស្តីពីការរំលោភ ការមិនយកចិត្តទុកដាក់ថែទាំ និងការធ្វើអាជីវកម្មលើកុមារ ជនចាស់ជរា និងជនបាត់បង់សមត្ថភាពពលកម្ម |
| អនុកម្មវិធីទី ២ កែលម្អសេវាការពារជនចាស់ជរា និង ជនបាត់បង់សមត្ថភាព ពលកម្ម | អនុកម្មវិធីទី ២ ការស៊ើបអង្កេត |
| គោលបំណង : បង្កើនប្រសិទ្ធភាពនៃការគាំពារជនចាស់ជរា និង ជនបាត់បង់សមត្ថភាពពលកម្ម ដើម្បីធានាសុវត្ថិភាព និង សន្តិសុខដែលរស់នៅគ្មានសុវត្ថិភាព និង សន្តិសុខក្នុងរយៈពេលវែង ដើម្បីកុំឱ្យមានការបំពាន ។ | គោលបំណង : ស៊ើបអង្កេតពាក្យបណ្តឹង ការរំលោភ ការមិនយកចិត្តទុកដាក់ថែទាំ និងការធ្វើអាជីវកម្ម |

គោលបំណងកម្មវិធី និង អនុកម្មវិធី គឺជាសារមួយដែលខ្លីតែមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដែលបង្ហាញពីគោលបំណង និងប្រាប់ពីមូលហេតុថា ហេតុអ្វីបានជាយើងត្រូវបង្កើតកម្មវិធី និងអនុកម្មវិធី ហើយគោលបំណង

នោះ ត្រូវមានទំនាក់ទំនងទៅនឹងលទ្ធផលចុងក្រោយ ។ ប្រសិនបើយើងកំណត់រចនាសម្ព័ន្ធកម្មវិធី និង អនុកម្មវិធី បានសមស្រប ការងារនៅក្នុងជំហានទី ៣ នេះនឹងមានលក្ខណៈងាយស្រួល ។

នៅក្នុងការកំណត់កម្មវិធី និង អនុកម្មវិធី ត្រូវធ្វើយ៉ាងណាឲ្យឆ្លើយតបទៅនឹងគោលបំណងនៃលទ្ធផលចុងក្រោយ ។ នៅក្នុងឧទាហរណ៍ទី ៤ ខាងលើ នៅក្នុងកូឡោន **"អាចទទួលយកបាន"** កម្មវិធីត្រូវចែកចេញជាអនុកម្មវិធីទៅតាមប្រភេទនៃអ្នកដែលត្រូវទទួលផល ហើយគោលបំណងអនុកម្មវិធីនីមួយៗ បានឆ្លើយតបទៅនឹងគោលបំណងនៃកម្មវិធី ។

នៅក្នុងឧទាហរណ៍ទី ៤ ខាងលើ នៅក្នុងកូឡោន **"មិនអាចទទួលយកបាន"** កម្មវិធីត្រូវបានចែកជាអនុកម្មវិធីទៅតាមដំណើរការ និងមុខងារ ។ នៅក្នុងគោលបំណងនៃអនុកម្មវិធី ដែលជាដំណើរការទទួលពាក្យបណ្តឹង និង ដំណើរការស៊ើបអង្កេតពុំមានទំនាក់ទំនងដោយផ្ទាល់ ឬឆ្លើយតបទៅនឹងគោលបំណងកម្មវិធីឡើយ ។ គ្មានដំណើរការណាមួយក្នុងចំណោមដំណើរការទាំងពីរ ដែលអាចនាំមកនូវលទ្ធផលចុងក្រោយ ដែលបានរំពឹងទុកនោះទេ ។ គោលបំណងនៃអនុកម្មវិធីទាំងពីរខាងលើអាចអនុវត្តបានល្អ ប៉ុន្តែមិនបានទទួលផលក្នុងការបង្កើនប្រសិទ្ធភាពនៃសេវាការពារសុវត្ថិភាពជូនកុមារ ស្ត្រីងាយរងគ្រោះ, ជនចាស់ជរា និង ជនបាត់បង់សមត្ថភាពពលកម្មបានឡើយ ។ អនុកម្មវិធីមិនមែនជាការបែងចែកខុសៗគ្នានៃកម្មវិធីនោះទេ ប៉ុន្តែវាគឺជាការបែងចែកដោយផ្អែកលើលទ្ធផលចុងក្រោយដែលរំពឹងទុក ។

**បន្ទាប់ពីការកំណត់គោលបំណងកម្មវិធី និង អនុកម្មវិធីរួចហើយ យើងអាចធ្វើការពិនិត្យឡើងវិញអំពីភាពសមស្រប ដោយលើកជាសំណួរមួយចំនួន ដូចខាងក្រោម ៖**

- **តើកម្មវិធី និង អនុកម្មវិធីបង្កើតឡើងមានភាពច្បាស់លាស់ឬទេ?**
- **តើគោលបំណងកម្មវិធី និង អនុកម្មវិធីបានឆ្លុះបញ្ចាំងពីគោលនយោបាយរបស់រាជរដ្ឋាភិបាលឬទេ?**
- **តើយើងអាចបង្កើតសូចនាករសម្រាប់វាស់វែងគោលបំណងកម្មវិធី និង អនុកម្មវិធីបានដែរឬទេ? ការធ្វើដូច្នេះ គឺដើម្បីដឹងថានៅពេលណាយើងនឹងសម្រេចបានតាមគោលបំណងនោះ ។**
- **តើគោលបំណងអនុកម្មវិធី មានទំនាក់ទំនងទៅនឹងគោលបំណងកម្មវិធី និង លទ្ធផលចុងក្រោយឬទេ? ហើយតើគោលបំណងអនុកម្មវិធីនោះ គាំទ្រដល់គោលបំណងកម្មវិធីឬទេ?**
- **តើគោលបំណងនៃកម្មវិធី និង អនុកម្មវិធី អាចជួយពង្រីកសមត្ថភាពមានភាពប្រាកដនិយម. និង អាចសម្រេចបានដែរឬទេ?**

សំណួរទាំងនេះ មានបំណងដើម្បីបញ្ជាក់ពីភាពសមស្របនៃគោលបំណងកម្មវិធី និងអនុកម្មវិធី ។ ដោយឈរលើមូលដ្ឋាននេះ យើងអាចផ្តល់អនុសាសន៍ដើម្បីឲ្យគោលបំណងនៃកម្មវិធី និង អនុកម្មវិធី មានភាពសមស្រប ។ ប្រសិនបើមិនសមស្របទេ យើងអាចធ្វើការផ្លាស់ប្តូរ ។

## ជំហានទី ៤ : វិធីសាស្ត្រក្នុងការកំណត់ខ្សែចង្វាក់លទ្ធផល

**(ជំហានទី ៤ នេះ បានផ្តល់នូវគំនិត និង សេចក្តីពន្យល់ ដើម្បីបំពេញព័ត៌មាននៅក្នុងតារាងឧបសម្ព័ន្ធ ទី ២.១ ដូចមានជូនភ្ជាប់មកជាមួយ)**

ជំហាននេះ នឹងផ្តោតជាពិសេសលើតក្ក និង វិធីសាស្ត្រនៃការកសាងទិន្នន័យសម្រាប់ខ្សែចង្វាក់លទ្ធផល។ ចំណែកការពន្យល់អំពីការកសាងសូចនាករដើម្បីវាស់វែង និងអធិប្បាយនៅក្នុងផ្នែកទី ២ នៃគោលការណ៍ណែនាំនេះ ។

នៅពេលដែលយើង បានកំណត់គោលបំណងកម្មវិធី និង អនុកម្មវិធីរួចហើយ អនុញ្ញាតឲ្យយើងជាបឋមធ្វើការបង្ហាញជូននូវដំណើរការពីលើចុះក្រោម/ពីក្រោមឡើងលើ (Top down/Bottom up iterative process) នៃខ្សែចង្វាក់លទ្ធផល (The Results Chain) ដូចដែលនឹងបង្ហាញនៅក្នុងតារាងទី ២ ខាងក្រោមនេះ ៖

**តារាងទី ២ ខ្សែចង្វាក់លទ្ធផល**




គោលគំនិតនៃការផ្សារភ្ជាប់រវាងចង្កោមសកម្មភាពទៅលទ្ធផលក្នុងឆ្នាំ និង លទ្ធផលចុងក្រោយ ដែលបានបង្ហាញក្នុងតារាងទី ២ ខាងលើ បានឆ្លុះបញ្ចាំងពីតក្កនៃខ្សែចង្វាក់លទ្ធផលរបស់កម្មវិធីមួយ ។ ខ្សែចង្វាក់លទ្ធផលរវាងលទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយដែលត្រូវកំណត់ជាសូចនាករសមិទ្ធកម្ម ដើម្បីអាចវាស់វែងពីលទ្ធផលដែលជាមូលដ្ឋានសម្រាប់ការតាមដានក្នុងការអនុវត្តកម្មវិធី ។

តារាងខាងក្រោមមានគោលបំណងពន្យល់ពីវាក្យានុក្រម និង តក្កនៃខ្សែចង្វាក់លទ្ធផលរបស់កម្មវិធី ។

**តារាងទី ៣ : វាក្យានុក្រមនៃខ្សែចង្វាក់លទ្ធផល**

| **ពាក្យ** | **អត្ថន័យ** | **ឧទាហរណ៍** |
|---|---|---|
| គោលបំណង **(Objective)** | ហេតុផលដែលត្រូវបង្កើតលទ្ធផលក្នុងឆ្នាំ និង លទ្ធផលចុងក្រោយ | ការកែលម្អគុណភាព និង ប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា |
| លទ្ធផលចុងក្រោយ **(Outcome)** | លទ្ធផលដែលទទួលបានពីការសម្រេចបាននូវលទ្ធផលក្នុងឆ្នាំ | ចំនួនគ្រូបង្រៀន ដែលបានយកបច្ចេកទេសថ្មីមកអនុវត្ត បន្ទាប់ពីទទួលបានតាមការបណ្តុះបណ្តាល |
| លទ្ធផលក្នុងឆ្នាំ **(Output)** | ទំនិញ និង សេវាដែលបានមកពីការអនុវត្តចង្កោមសកម្មភាព | ចំនួនវគ្គបណ្តុះបណ្តាលគ្រូបង្រៀន, ចំនួនគ្រូដែលទទួលបានការបណ្តុះបណ្តាលវគ្គបច្ចេកទេសថ្មី |

| | | |
|---|---|---|
| សកម្មភាពការងារ (Activities) | ជាក្រុមនៃសកម្មភាពដែលមានគោលបំណងច្បាស់លាស់ នៅក្នុងអនុកម្មវិធី | ការរៀបចំវគ្គបណ្តុះបណ្តាលគ្រូ ឬការកសាងវិទ្យាស្ថាន សម្រាប់បណ្តុះបណ្តាលគ្រូ |

ឧទាហរណ៍ ភាពតក្កនៃកម្មវិធី (Program Logic) ដែលមានបង្ហាញនៅក្នុងតារាងទី ៣ មានសង្គតិភាពទៅនឹងតារាងទី ២ ។

ឈរលើមូលដ្ឋានវិភាគខាងលើនេះ យើងត្រូវកំណត់ពីលទ្ធផលក្នុងឆ្នាំ និង លទ្ធផលចុងក្រោយ ដើម្បីសម្រេចបានគោលបំណងនៃកម្មវិធី បន្ទាប់មកទៀតយើងត្រូវកំណត់ពីចង្កោមសកម្មភាពដែលត្រូវអនុវត្ត ដើម្បីទទួលបានលទ្ធផលក្នុងឆ្នាំ ។

**ក. លទ្ធផលចុងក្រោយ (Outcome)**

**(ចំណុច ក. នេះ មានសារសំខាន់ សម្រាប់បំពេញតារាងឧបសម្ព័ន្ធទី ២.១ ជួរឈរទី ៤ និងទី ៥)**

លទ្ធផលចុងក្រោយត្រូវកំណត់យ៉ាងណា ដើម្បីអាចវាស់វែងបាន (Measurable Result) និង ធានាថាគោលបំណងនៃកម្មវិធី អាចសម្រេចបានតាមការគ្រោងទុក ។ កម្មវិធីនីមួយៗ ត្រូវមានលទ្ធផលចុងក្រោយមួយយ៉ាងតិច ។ ចំពោះអនុកម្មវិធី ក៏អាចមានលទ្ធផលចុងក្រោយមួយដែរ តែអាស្រ័យទៅលើលក្ខណៈជាក់ស្តែងនៃកម្មវិធី ព្រោះថាជាទូទៅអនុកម្មវិធីបង្កើតបានលទ្ធផលក្នុងឆ្នាំដែលជាចំណែកមួយ ដើម្បីបង្កើតលទ្ធផលចុងក្រោយ ។

ការកំណត់លទ្ធផលចុងក្រោយ ត្រូវពិចារណាលើលក្ខណៈសម្បត្តិមួយចំនួន ដូចខាងក្រោម ៖

- ឆ្លុះបញ្ចាំងពីគោលបំណងច្បាស់លាស់នៃកម្មវិធី ។
- ឆ្លុះបញ្ចាំងពីលទ្ធផល ដែលកម្មវិធីចង់បាន ។
- មានសូចនាករដែលអាចធ្វើការតាមដាន និង វាយតម្លៃលទ្ធផលបាន (វិធីសាស្ត្រនៃការកំណត់ នឹងពន្យល់ នៅក្នុងផ្នែកទី ៣) ។
- ត្រូវកំណត់ឱ្យបានច្បាស់ចំពោះអ្នកដែលត្រូវទទួលផលពីការអនុវត្តកម្មវិធី ។
- លទ្ធផលចុងក្រោយ គួរត្រូវមានការពិគ្រោះយោបល់ឱ្យបានទូលាយ ជាពិសេសលទ្ធផលចុងក្រោយដែលត្រូវរួមចំណែកសម្រេចដោយភាគីច្រើន ។ ការពិគ្រោះយោបល់នេះ គឺដើម្បីជៀសវាងការលើកកម្មវិធីត្រួតគ្នា និង ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការបែងចែកមុខងារ និង ភារកិច្ចរវាងភាគីពាក់ព័ន្ធ ។

គោលការណ៍ណែនាំនេះ គ្រាន់តែជាមូលដ្ឋានជួយណែនាំ ពីការកំណត់លទ្ធផលចុងក្រោយប៉ុណ្ណោះ តែមិនមានបំណងកំណត់នូវលទ្ធផលចុងក្រោយជាក់លាក់ ដែលជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញរាជធានី ខេត្តទេ ។

ទិដ្ឋភាពដែលលំបាកមួយក្នុងការកំណត់ពីលទ្ធផលចុងក្រោយ គឺការធានាថាលទ្ធផលចុងក្រោយ អាចវាស់វែងបាន ជាពិសេសទាក់ទងនឹងភាពសមស្រប ភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាព ។ លទ្ធផលចុងក្រោយ

ភាគច្រើនអាចត្រូវទទួលរងឥទ្ធិពលពីកត្តាខាងក្រៅ ដែលក្រសួងសាមីមិនអាចត្រួតត្រាបាន និង/ឬទទួលរងឥទ្ធិពលពីកត្តាផ្សេងៗទៀត ដែលមានការពាក់ព័ន្ធទៅនឹងវិស័យជាច្រើន ។

ឧទាហរណ៍ លទ្ធផលក្នុងឆ្នាំនៃការបង្រៀន រួមមាន ចំនួនកូនសិស្សដែលទទួលការបណ្តុះបណ្តាលនៅក្នុងសាលា ហើយលទ្ធផលចុងក្រោយនៃសិស្សដែលបានប្រលងជាប់ ត្រូវស្ថិតនៅក្រោមឥទ្ធិពលមួយចំនួន ដូចជាការតាំងចិត្តរៀនសូត្ររបស់សិស្សដើម្បីប្រលងជាប់ ។ ក្រសួង អាចមានឥទ្ធិពលតែទៅលើចំនួនសិស្ស ដែលទទួលការបណ្តុះបណ្តាលក្នុងសាលា ប៉ុន្តែមានកត្តាមួយចំនួនទៀតដែលក្រសួងមិនអាចត្រួតត្រាបាន ហើយកត្តានេះ អាចកំណត់បានមួយផ្នែកពីគុណភាពនៃការបង្រៀន ដើម្បីទទួលបានអត្រាប្រលងជាប់ខ្ពស់ ។

យើងមិនត្រូវយល់ច្រឡំរវាងលទ្ធផលចុងក្រោយ និង លទ្ធផលក្នុងឆ្នាំទេ ។ លទ្ធផលចុងក្រោយ គឺជាអ្វីដែលយើងទទួលបានពីលទ្ធផលក្នុងឆ្នាំ ។ ឧទាហរណ៍ "ការកសាងប្រព័ន្ធធារាសាស្ត្រ" គឺជាលទ្ធផលក្នុងឆ្នាំ រីឯ "ការបង្កើនផលិតកម្មស្រូវ" គឺជាលទ្ធផលចុងក្រោយដែលបានទទួលរងឥទ្ធិពលពីការកសាងប្រព័ន្ធធារាសាស្ត្រ ធ្វើឲ្យប្រជាកសិករមានទឹកគ្រប់គ្រាន់ សម្រាប់ធ្វើស្រែបានច្រើនដងក្នុងមួយឆ្នាំ ទើបផលិតកម្មស្រូវមានការកើនឡើង ។

## សំណួរដែលត្រូវសួរដើម្បីកំណត់ថា តើលទ្ធផលចុងក្រោយដែលបានដាក់ចេញមានភាពសមស្របដែរឬទេ?

បន្ទាប់ពីបានកំណត់លទ្ធផលចុងក្រោយសម្រាប់កម្មវិធី និង អនុកម្មវិធីរួចហើយ យើងត្រូវពិនិត្យលើភាពសមស្របរបស់លទ្ធផលចុងក្រោយទាំងនោះ ។ ដើម្បីជាគំនិត គួរធ្វើការចោទសួរនូវសំណួរមួយចំនួន ដូចខាងក្រោម ៖

- តើលទ្ធផលចុងក្រោយដែលបានកំណត់ នឹងផ្តល់នូវលទ្ធផលរំពឹងទុកដ៏ច្បាស់លាស់ សម្រាប់កម្មវិធីឬទេ?
- តើលទ្ធផលចុងក្រោយបានឆ្លុះបញ្ចាំងពីគោលបំណងរបស់កម្មវិធីដែរឬទេ?
- តើយើងអាចតាមដានលទ្ធផលចុងក្រោយ និង កំណត់ពីពេលវេលាដែលសម្រេចបានលទ្ធផលចុងក្រោយនោះដែរឬទេ?
- តើលទ្ធផលចុងក្រោយដែលបានកំណត់នេះ មានលក្ខណៈសាមញ្ញ និង ងាយយល់សម្រាប់អ្នកដែលមិនមានកម្រិតយល់ដឹងច្បាស់លាស់ ពីកម្មវិធី និង/ឬ អនុកម្មវិធីដែរឬទេ?

សំណួរខាងលើនេះ គ្រាន់តែជាមូលដ្ឋានសម្រាប់បញ្ជាក់ពីភាពសមស្របនៃលទ្ធផលចុងក្រោយ ហើយក៏អាចមានសំណួរជាច្រើនទៀត ទៅតាមវិស័យនីមួយៗ ដែលគួរយកមកពិចារណាបន្ថែមនៅក្នុងដំណើរការនៃការកំណត់លទ្ធផលចុងក្រោយ ។

**១. ការកំណត់ពីលទ្ធផលក្នុងឆ្នាំ (Output)**

**(ចំណុច ១. នេះ មានសារសំខាន់ សម្រាប់បំពេញតារាងឧបសម្ព័ន្ធទី ២.១ ជួរឈរទី ៥ និងទី ១០)**

លទ្ធផលក្នុងឆ្នាំគឺជាការទទួលបាននូវទំនិញ សំណង់ ឬ ការផ្តល់សេវាកម្មផ្សេងៗ ដូចជាសាលារៀន មន្ទីរពេទ្យជាដើម ។ល។ ដែលបង្កើតឡើងដោយភ្នាក់ងារសាធារណៈ ឈានទៅសម្រេចបានលទ្ធផលចុងក្រោយ និង ឈានទៅសម្រេចគោលបំណងនៃកម្មវិធីដែលយើងចង់បាន ។ កម្មវិធីនីមួយៗ ត្រូវបង្កើតនូវលទ្ធផលក្នុងឆ្នាំមួយចំនួន ហើយអនុកម្មវិធីត្រូវបង្កើតយ៉ាងតិចបំផុតនូវលទ្ធផលក្នុងឆ្នាំមួយ ។

ក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្ត ដែលជាអង្គភាពចំណាយមានភារកិច្ចត្រួតពិនិត្យដោយផ្ទាល់ទៅលើលទ្ធផលក្នុងឆ្នាំ ។ គួរកត់សម្គាល់ថា នៅក្នុងវិស័យខ្លះអាចមានភាពងាយស្រួលក្នុងការកំណត់នូវលទ្ធផលក្នុងឆ្នាំដែលត្រូវបានបង្កើត ឧទាហរណ៍ដូចជាចំនួនសិស្សដែលត្រូវទទួលបានការបណ្តុះបណ្តាល, ប្រវែងផ្លូវដែលត្រូវបានជួសជុល, ចំនួនអ្នកជំងឺដែលត្រូវទទួលបានការព្យាបាល, ផលស្រូវមួយហិកតាក្នុងមួយឆ្នាំ ។ ប៉ុន្តែវិស័យដទៃទៀត ដូចជាវិស័យរដ្ឋបាលទូទៅអាចមានការលំបាកក្នុងកំណត់លទ្ធផលក្នុងឆ្នាំ ឧទាហរណ៍ : ការរៀបចំច្បាប់ និង អនុវត្តច្បាប់, ការផ្តល់សេវាការពារជាតិ, ការការពារអធិបតេយ្យភាព បូរណភាពទឹកដី, ការធ្វើសមាហរណកម្មក្នុងតំបន់ និង ពិភពលោក ។

លទ្ធផលក្នុងឆ្នាំទាំងអស់ ត្រូវរួមចំណែកដល់ការបង្កើតលទ្ធផលចុងក្រោយជាក់លាក់ណាមួយ ។ ដូច្នេះ លទ្ធផលក្នុងឆ្នាំ គឺជាស្នូលដ៏សំខាន់មួយរបស់កម្មវិធី និង អនុកម្មវិធី ព្រោះលទ្ធផលក្នុងឆ្នាំបង្កើតជាលទ្ធផលចុងក្រោយ ដើម្បីសម្រេចបានគោលបំណងរបស់កម្មវិធី ។

ការកំណត់លទ្ធផលក្នុងឆ្នាំ ត្រូវពិចារណាលើលក្ខណៈសម្បត្តិមួយចំនួន ដូចខាងក្រោម ៖

- ប្រភេទ និង លក្ខណៈជាក់លាក់នៃទំនិញដែលត្រូវបានបង្កើត និង សេវាកម្មដែលត្រូវបានផ្តល់
- ចំនួនអ្នកដែលត្រូវទទួលបានផលពីការផ្តល់ទំនិញ និង សេវា
- កំណត់គុណភាព ឬ ស្តង់ដារនៃទំនិញ និង សេវា ដែលត្រូវបានបង្កើត
- កំណត់លទ្ធផលដែលបង្កើតពាក់ព័ន្ធនឹងបរិមាណ គុណភាព និង ពេលវេលាជាក់លាក់នៃការផ្តល់ទំនិញ និង សេវា ។

## សំណួរ ដែលត្រូវសួរដើម្បីកំណត់ថា តើលទ្ធផលក្នុងឆ្នាំដែលបានដាក់ចេញ មានភាពសម-ស្របដែរឬទេ?

នៅពេលដែលយើង បានកំណត់ពីលទ្ធផលក្នុងឆ្នាំរួចហើយ ចំណុចដែលសំខាន់នោះ គឺត្រូវកំណត់ថាតើលទ្ធផលក្នុងឆ្នាំទាំងនោះមានភាពសមស្របឬទេ ដោយធ្វើការចោទសួរជាសំណួរ ដូចខាងក្រោម ៖

- តើលទ្ធផលក្នុងឆ្នាំមានភាពស័ក្តិសិទ្ធិដែរឬទេ ដើម្បីរួមចំណែកដល់លទ្ធផលចុងក្រោយ?
- តើលទ្ធផលក្នុងឆ្នាំអាចធ្វើការវាស់វែងបានដែរឬទេចំពោះបរិមាណ គុណភាព និង ពេលវេលា? (វិធីសាស្ត្រនៃការកំណត់ នឹងពន្យល់នៅផ្នែកទី ៣)

- តើលទ្ធផលក្នុងឆ្នាំត្រូវបានកំណត់ដោយផ្តោតទៅលើអ្វីដែលត្រូវបង្កើត ជាងអ្វីដែលត្រូវធ្វើ (ដូចជាសកម្មភាពការងារដែលត្រូវអនុវត្ត)?
- តើរាជរដ្ឋាភិបាលត្រូវចំណាយទៅលើអ្វី និង ទទួលបានអ្វីត្រឡប់មកវិញ?
- តើលទ្ធផលក្នុងឆ្នាំស្ថិតនៅក្រោមការត្រួតត្រារបស់ក្រសួងដែរឬទេ?

សំណួរខាងលើនេះ គ្រាន់តែជាមូលដ្ឋានសម្រាប់បញ្ជាក់ពីភាពសមស្របនៃលទ្ធផលក្នុងឆ្នាំ ហើយក៏អាចមានសំណួរផ្សេងៗតាមវិស័យនីមួយៗ ដែលគួរយកមកពិចារណាបន្ថែមទៀតនៅក្នុងដំណើរការនៃការកំណត់លទ្ធផលក្នុងឆ្នាំ ។

**គ. ការកំណត់ពីចង្កោមសកម្មភាព (Activities)**

**(ចំណុច គ. នេះ មានសារសំខាន់ សម្រាប់បំពេញតារាងឧបសម្ព័ន្ធទី ២.១ ជួរឈរទី ១)**

ចង្កោមសកម្មភាព គឺជាបណ្តុំសកម្មភាព (Actions) ដែលមានគោលបំណងច្បាស់លាស់នៅក្នុងអនុកម្មវិធី ។ ឧទាហរណ៍ចង្កោមសកម្មភាពមួយ គឺ "ការរៀបចំ និង ដាក់ឲ្យអនុវត្តនូវចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា" ដែលតម្រូវឲ្យមានសកម្មភាពមួយចំនួន ដូចជាការបង្កើតក្រុមការងារ ការប្រជុំពិភាក្សា ការរៀបចំសេចក្តីព្រាងការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ការអនុម័តរបស់ថ្នាក់ដឹកនាំ និង សិក្ខាសាលា ផ្សព្វផ្សាយ អនុវត្ត ។ យើងគួរកត់សម្គាល់ថាសកម្មភាពលំអិត (Actitions) ដែលបានរៀបរាប់នៅក្នុងឧទាហរណ៍ខាងលើជាសកម្មភាពដែលចាំបាច់ដើម្បីសម្រេចលទ្ធផលនៃសកម្មភាព ក៏ប៉ុន្តែសកម្មភាពលំអិតទាំងនេះ មិនតម្រូវឲ្យឆ្លុះបញ្ចាំងនៅក្នុងរចនាសម្ព័ន្ធនៃថវិកាកម្មវិធីទេ ។

នៅក្នុងថវិកាកម្មវិធី ចង្កោមសកម្មភាពនីមួយៗសុទ្ធតែមានគោលបំណង និង គោលដៅជាក់លាក់មួយដែលរួមចំណែកដល់ការសម្រេចគោលបំណងរបស់កម្មវិធី ។ ដូច្នេះ ចង្កោមសកម្មភាពនីមួយៗ ត្រូវតែមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងគោលបំណងនៃកម្មវិធី ហើយចំនួនចង្កោមសកម្មភាព គួរកម្រិតនៅត្រឹមចំនួនមួយដែលអាចគ្រប់គ្រងបាន ។

ចង្កោមសកម្មភាព ជាទូទៅមាន ៤ ប្រភេទ ៖

**១. ចង្កោមសកម្មភាពរដ្ឋបាល** គឺជាចង្កោមសកម្មភាពដែលទាក់ទងទៅនឹងដំណើរការរបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្ត ដែលរួមមានការគ្រប់គ្រងបុគ្គលិក ការងារទំនាក់ទំនង និង ការចំណាយជាប្រចាំ រួមមាន ទឹក ភ្លើង ការថែទាំអគារ និង សម្ភារៈការិយាល័យជាដើម ។ គួរកត់សម្គាល់ថា ចង្កោមសកម្មភាពរដ្ឋបាលមានលក្ខណៈជាការងារគាំទ្រដល់ប្រតិបត្តិការ និង ការគ្រប់គ្រងរួមរបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្ត ដែលអាចមានលក្ខណៈលំបាកក្នុងការបែងចែកចំណាយប្រភេទនេះ ទៅតាមកម្មវិធី និង អង្គភាពចំណាយនីមួយៗឲ្យបានច្បាស់លាស់ ។

**២. ចង្កោមសកម្មភាពសេវាកម្ម** គឺជាចង្កោមសកម្មភាព ដែលទាក់ទងទៅនឹងការផ្តល់សេវាសាធារណៈ, ឧទាហរណ៍ ការផ្តល់សេវាសុខាភិបាល ដូចជាការវះកាត់ ការចាក់ថ្នាំបង្ការ ការពិគ្រោះយោបល់ សេវាអប់រំក្នុងសាលារៀន មានដូចជា ការបង្រៀន ការផ្តល់សៀវភៅអាន ។ល។

**៣. ចង្កោមសកម្មភាពវិនិយោគ** គឺជាចង្កោមសកម្មភាព ដែលទាក់ទងទៅនឹងការទទួលបានអចលនទ្រព្យ តាមរយៈការទិញ ឬ ការសាងសង់ ។ ឧទាហរណ៍ ការកសាងផ្លូវ សាលារៀន គ្លីនិកព្យាបាល ការទិញសម្ភារៈបរិក្ខារធំៗ ។ល។ ប៉ុន្តែ គួរកត់សម្គាល់ថា ចង្កោមសកម្មភាពវិនិយោគភាគច្រើនត្រូវអនុវត្ត ដើម្បីគាំទ្រដល់ការបង្កើតលទ្ធផលក្នុងឆ្នាំ និង ចង្កោមសកម្មភាពសេវាផ្សេងៗ ដើម្បីឈានទៅសម្រេចបានគោលបំណងរបស់កម្មវិធី ។ ឧទាហរណ៍ ការកសាងថ្នាក់រៀនបន្ថែមដែលជាចង្កោមសកម្មភាពវិនិយោគ គឺដើម្បីគាំទ្រដល់លទ្ធផលក្នុងឆ្នាំគឺការ "បង្កើនចំនួនថ្នាក់រៀន" ដែលជាកត្តាគាំទ្រដល់គោលបំណងនៃ "ការអប់រំសម្រាប់ទាំងអស់គ្នា" ។

**៤. ចង្កោមសកម្មភាពសេវាកម្ម និង រដ្ឋបាលដែលអាចកើតចេញមកពីការវិនិយោគថ្មី ។**

## សំណួរ ដែលត្រូវសួរដើម្បីកំណត់ថា តើចង្កោមសកម្មភាពដែលបានដាក់ចេញ មានភាពសមស្របដែរឬទេ?

នៅពេលដែលយើង បានកំណត់ពីចង្កោមសកម្មភាពរួចហើយ ចំណុចដែលសំខាន់នោះគឺត្រូវកំណត់ថា តើចង្កោមសកម្មភាពទាំងនោះមានភាពសមស្របឬទេ ដោយធ្វើការចោទសួរជាសំណួរ ដូចខាងក្រោម ៖

**ភាពសមស្រប (Appropriateness)**

- តើចង្កោមសកម្មភាពនឹងបង្កើតលទ្ធផលក្នុងឆ្នាំ តាមការរំពឹងទុកដែរឬទេ?
- តើចង្កោមសកម្មភាពមានភាពចាំបាច់សម្រាប់បង្កើតលទ្ធផលក្នុងឆ្នាំដែរឬទេ?
- តើមានចង្កោមសកម្មភាពណាដែលបង្កើតលទ្ធផលក្នុងឆ្នាំដូចគ្នា?

**លទ្ធភាព ដែលអាចអនុវត្តបាន (Feasibility)**

- តើចង្កោមសកម្មភាពអាចអនុវត្តបានតាមលក្ខណៈបច្ចេកទេសដែរឬទេ?
- តើមានជម្រើសផ្នែកបច្ចេកទេសដែរឬទេ? ប្រសិនបើមាន តើជម្រើសមួយណាដែលល្អ?
- តើធនធាន ឬ ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ អាចប្រើប្រាស់មានប្រសិទ្ធភាពដែរឬទេ? ជាជាងការទិញសម្ភារៈបរិក្ខារថ្មី ឬ សាងសង់អគារថ្មី?

**សមត្ថភាព (Capacity)**

- តើមានសមត្ថភាពចាំបាច់គ្រប់គ្រាន់រួចហើយឬនៅសម្រាប់អនុវត្តចង្កោមសកម្មភាព ដើម្បីបង្កើតលទ្ធផលក្នុងឆ្នាំដែរឬទេ?

- ប្រសិនបើបញ្ហាសមត្ថភាពនៅមានកម្រិតហើយគ្មានធនធានបន្ថែម តើគួរចាត់វិធានការបែបណា ដើម្បីកែលម្អសមត្ថភាព?

**លទ្ធផល ដែលមិនបានគិតទុក (Unintended Results)**

- តើមានលទ្ធផលជាអវិជ្ជមាន (ឧទាហរណ៍ ការធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន) ដែរឬទេ?
- ប្រសិនបើមាន តើមានវិធានការអ្វី ដើម្បីកាត់បន្ថយលទ្ធផលអវិជ្ជមាននេះដែរឬទេ?

សំណួរខាងលើនេះ គ្រាន់តែជាមូលដ្ឋានសម្រាប់បញ្ជាក់ពីភាពសមស្របនៃចង្កោមសកម្មភាព ហើយក៏អាចមានសំណួរច្រើនទៀតតាមវិស័យនីមួយៗ ដែលគួរយកមកពិចារណាបន្ថែមនៅក្នុងដំណើរការនៃការកំណត់ចង្កោមសកម្មភាព ។

## ជំហានទី ៥ : ពិនិត្យឡើងវិញ អំពីតក្កនៃការកសាងរចនាសម្ព័ន្ធកម្មវិធី

**(ជំហានទី ៥ នេះ ផ្តល់នូវគំនិត និង សេចក្តីពន្យល់ ដើម្បីផ្ទៀតផ្ទាត់តក្កភាពនៃព័ត៌មានដែលបានបំពេញនៅក្នុងតារាងឧបសម្ព័ន្ធទី ២.១ ដូចមានជូនភ្ជាប់មកជាមួយ)**

ជាក់ស្តែង ការកសាងថវិកាកម្មវិធី គឺជាដំណើរការមួយដែលទាមទារនូវការពិនិត្យសារចុះសារឡើង ដើម្បីធានាសង្គតិភាពនៃការរៀបចំកម្មវិធី ហើយគោលបំណងនៃកម្មវិធីឆ្លើយតបទៅនឹងគោលបំណងគោលនយោបាយ ។ ការណែនាំការរៀបចំជាជំហានៗនេះ គ្រាន់តែជាលំដាប់លំដោយដំបូងប៉ុណ្ណោះ ក្នុងការអនុវត្តជាក់ស្តែងក្រុមការងារថវិកាអាចពិនិត្យពិចារណា អំពីដំណើរការនៃការរៀបចំទៅតាមស្ថានភាពជាក់ស្តែងដោយមិនទាមទារថា ត្រូវតែដើរតាមលំដាប់លំដោយនៃជំហានៗ ដូចបានរៀបរាប់ខាងលើនេះទេ ។

ហេតុនេះ សំខាន់បំផុតនៅពេលក្រុមការងារថវិកា កសាងថវិកាកម្មវិធីត្រូវពិនិត្យសារចុះសារឡើងដើម្បីរំលេចឱ្យឃើញ ដូចតទៅ ៖

**១. រចនាសម្ព័ន្ធកម្មវិធី** ត្រូវរំលេចឱ្យឃើញពីបេសកកម្មរបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្ត ។ ក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្ត គឺជានីតិបុគ្គលមានសិទ្ធិអំណាច កំណត់ដោយច្បាប់ ដើម្បីសម្រេចនូវបេសកកម្មដែលជាកាតព្វកិច្ច ដើម្បីសម្រេចឱ្យខាងតែបាន ។

**២. រចនាសម្ព័ន្ធកម្មវិធី** ត្រូវរំលេចឱ្យឃើញពីគោលបំណងនៃគោលនយោបាយរបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្ត ។ រចនាសម្ព័ន្ធកម្មវិធី ក៏ត្រូវរំលេចឱ្យឃើញផងដែរពីគោលនយោបាយថ្មី ប្រសិនបើមាន ដើម្បីរក្សានូវសង្គតិភាពរវាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង ផែនការយុទ្ធសាស្ត្រថវិកា ។

**៣. រចនាសម្ព័ន្ធកម្មវិធី** ត្រូវបង្កើតឡើងដោយផ្អែកលើបេសកកម្ម ដែលត្រូវបានកំណត់របស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្ត ដើម្បីអាចធានាបាននូវគណនេយ្យភាពច្បាស់លាស់ និង សម្រួលដល់ការ

កំណត់ចង្កោមសកម្មភាព លទ្ធផលក្នុងឆ្នាំ និង លទ្ធផលចុងក្រោយ ជៀសវាងការត្រួតគ្នាជាមួយក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្តដទៃ ។

**៤. រចនាសម្ព័ន្ធកម្មវិធីក្រសួងនីមួយៗ** ត្រូវកំណត់ឲ្យមានត្រឹមតែ ៥ ដើម្បីសម្រួលដល់ការគ្រប់គ្រង និង ការអនុវត្តកម្មវិធី ។

**៥. កម្មវិធីមួយ** អាចមានសមាសភាគផ្សេងៗគ្នាមួយចំនួនដែលធ្វើឲ្យយើងមានការពិបាក ដើម្បីដាក់ចេញនូវវិធានការសម្រាប់អនុវត្ត ។ នៅក្នុងករណីនេះ កម្មវិធីអាចបំបែកជាអនុកម្មវិធីមួយចំនួន អាស្រ័យទៅលើរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្ត ។

**៦. រចនាសម្ព័ន្ធកម្មវិធី** រួមមានកម្មវិធី អនុកម្មវិធី និង ចង្កោមសកម្មភាព ។ ប៉ុន្តែ នៅក្នុងការអនុវត្ត ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងផ្តោតការត្រួតពិនិត្យតាមដានត្រឹមកម្រិតកម្មវិធី និង អនុកម្មវិធី ។ ចំពោះកម្រិតចង្កោមសកម្មភាពជាកាតព្វកិច្ចនៃការគ្រប់គ្រង ការទទួលខុសត្រូវ និង ការពិនិត្យតាមដានដោយផ្ទាល់របស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្ត ។

**៧. ចំពោះឈ្មោះនៃកម្មវិធី និង អនុកម្មវិធី** ត្រូវមានលក្ខណៈជាការពិពណ៌នា (Descriptive) ពន្យល់ពីបញ្ហាដែលកម្មវិធី ឬ អនុកម្មវិធីចង់ដោះស្រាយ ។ រីឯគោលបំណងកម្មវិធី និង អនុកម្មវិធី ត្រូវមានលក្ខណៈច្បាស់លាស់ ព្រោះត្រូវឆ្លើយតបទៅនឹងបេសកកម្ម និង គោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្ត ។

## ២.២. ការកំណត់សូចនាករសមិទ្ធកម្ម

ផ្នែកនេះ ផ្តល់ការណែនាំ ពីការកំណត់សូចនាករសមិទ្ធកម្ម (Performance Indicator) ដើម្បីតាមដានវឌ្ឍនភាព និង សមិទ្ធផលនៃកម្មវិធី អនុកម្មវិធី និង ចង្កោមសកម្មភាព ព្រមទាំងផ្តល់នូវលក្ខខណ្ឌវិនិច្ឆ័យមួយចំនួនដើម្បីពិនិត្យមើលថា តើសូចនាករសមិទ្ធកម្មដែលបានកំណត់មានភាពសមស្របដែរឬទេ? ។

### ជំហានទី ៦ : វិធីសាស្ត្រក្នុងការកំណត់សូចនាករសមិទ្ធកម្ម

**(ជំហានទី ៦ នេះ ផ្តល់នូវគំនិត និង សេចក្តីពន្យល់ ដើម្បីអាចបំពេញព័ត៌មាននៅក្នុង តារាងឧបសម្ព័ន្ធទី ២.១ ដូចមានជូនភ្ជាប់មកជាមួយ)**

សូចនាករសមិទ្ធកម្ម ត្រូវតែអាចកំណត់គោលដៅ ដែលជារង្វាស់សម្រាប់តាមដានសមិទ្ធផល ដែលបានឯកភាព ។ សូចនាករដើរតួនាទីដ៏សំខាន់ក្នុងការកំណត់គោលដៅ ដែលអាចមានលក្ខណៈជាបរិមាណ ឬ ជាគុណភាព ។ គួរកំណត់ចំនួនសូចនាករនៅក្នុងកម្រិតមួយសមស្រប និង គ្រប់គ្រាន់សម្រាប់វាស់វែងការផ្លាស់ប្តូរសមិទ្ធកម្ម ជៀសវាងការមានសូចនាករច្រើនដែលនាំឲ្យមានការលំបាកដល់ការប្រមូល និង ការវិភាគទិន្នន័យសម្រាប់វាស់វែងការផ្លាស់ប្តូរសមិទ្ធកម្ម ។

ខាងក្រោមនេះ គឺជាឧទាហរណ៍នៃសូចនាករ ដែលជាគោលដៅសមិទ្ធកម្មនៃការជួសជុលផ្លូវ ៖

- ប្រវែងផ្លូវ (គីឡូម៉ែត្រ) ដែលត្រូវជួសជុល គឺជាបរិមាណនៃលទ្ធផលក្នុងឆ្នាំដែលបានឯកភាព ។
- ផ្លូវដែលត្រូវជួសជុលត្រូវមានគុណភាពតាមស្តង់ដារកំណត់ គឺជាគុណភាពនៃលទ្ធផលក្នុងឆ្នាំដែលបានឯកភាព ។
- ផ្លូវដែលត្រូវជួសជុល ត្រូវសម្រេចឲ្យបានទាន់ពេលវេលា និង ទៅតាមតម្លៃដែលបានឯកភាព ។

ការសម្រេចបាននូវគោលបំណងនៃកម្មវិធី គឺជាមូលដ្ឋានដ៏សំខាន់នៃការអនុវត្តចំណាយថវិកា ក្នុងន័យនេះ ទំនាក់ទំនងរវាងសូចនាករលទ្ធផលក្នុងឆ្នាំ និង សូចនាករលទ្ធផលចុងក្រោយគឺជាប្រការសំខាន់ នឹងត្រូវឆ្លើយតបគ្នា ដើម្បីធានាបាននូវការវាស់វែងឲ្យនូវការវាស់វឌ្ឍនភាពគោលបំណងនៃកម្មវិធីប្រកបដោយប្រសិទ្ធភាព ។

**តារាងទី ៤ ការវាស់វែងសមិទ្ធកម្មដែលសម្រេចបាន**

| សូចនាករ | និយមន័យ | ការពន្យល់ |
|---|---|---|
| លទ្ធផលចុងក្រោយ | ជាលទ្ធផលសម្រេចបានពីមួយឆ្នាំទៅមួយឆ្នាំ ក្រោយពីការអនុវត្តបានពេញលេញ នូវអនុកម្មវិធី និង កម្មវិធីក្នុងរយៈពេលកំណត់មួយ | ជារង្វាស់លើសមិទ្ធកម្មនៃអនុកម្មវិធី ឬ កម្មវិធី នៃគោលបំណងគោលនយោបាយ |
| លទ្ធផលក្នុងឆ្នាំ | សមិទ្ធផលដែលទទួលបានពីការអនុវត្តចប់សព្វគ្រប់នៃចង្កោមសកម្មភាព អនុកម្មវិធី ឬ កម្មវិធី ។ | ជារង្វាស់លើសមិទ្ធកម្មនៃចង្កោមសកម្មភាព អនុកម្មវិធី ឬ កម្មវិធី ។ |

**សូចនាករលទ្ធផលចុងក្រោយ**

**(ចំណុចនេះផ្តល់នូវគំនិត និង សេចក្តីពន្យល់ ដើម្បីបំពេញព័ត៌មានក្នុងតារាងឧបសម្ព័ន្ធទី ២.១ ជួរឈរទី ៤ និងទី ៥)**

លក្ខណៈសម្បត្តិដ៏សំខាន់នៃសូចនាករលទ្ធផលចុងក្រោយ គឺជាភាពស័ក្តិសិទ្ធិដែលលទ្ធផលក្នុងឆ្នាំ ផ្តល់ក្នុងកម្រិតអតិបរមាដល់លទ្ធផលចុងក្រោយ ។ ម្យ៉ាងទៀត យើងគួរយល់ថា សូចនាករលទ្ធផលចុងក្រោយ គឺជារង្វាស់នៃបណ្តុំលទ្ធផលក្នុងឆ្នាំដែលបានបង្កើត ។

សូចនាករលទ្ធផលចុងក្រោយ ជាឧបករណ៍សម្រាប់វាស់លទ្ធផលចុងក្រោយនៃការបង្កើតលទ្ធផលក្នុងឆ្នាំ។

**ឧទាហរណ៍នៃសូចនាករលទ្ធផលចុងក្រោយ មានលក្ខណៈដូចខាងក្រោម ៖**

- អត្រាទទួលបានការងារធ្វើនៃនិស្សិតបញ្ចប់ការសិក្សា
- អត្រាកើនឡើងនៃផលិតភាពកសិកម្ម ធៀបនឹង ៥ ឆ្នាំមុន
- អត្រាកំណើននៃទិន្នផលស្រូវប្រចាំឆ្នាំ
- អត្រានៃជំងឺឆ្លងត្រូវបានកាត់បន្ថយ

- ចំនួនប្រជាជនដែលទទួលបានទឹកស្អាតប្រកបដោយសុវត្ថិភាព ។

**សូចនាករលទ្ធផលក្នុងឆ្នាំ**

**(ចំណុចនេះផ្តល់នូវគំនិត និង សេចក្តីពន្យល់ ដើម្បីបំពេញព័ត៌មានក្នុងតារាងឧបសម្ព័ន្ធទី ២.១ ជួរឈរទី ៥,៦,៧ និងទី ១០,១១,១២)**

លក្ខណៈសម្បត្តិដ៏សំខាន់នៃសូចនាករលទ្ធផលក្នុងឆ្នាំ គឺជាប្រសិទ្ធភាពចំណាយនៃការបង្កើតលទ្ធផលក្នុងឆ្នាំ ពោលគឺធ្វើយ៉ាងណាឲ្យការចំណាយក្នុងមួយឯកតាស្ថិតក្នុងកម្រិតអប្បបរមា ។ សូចនាករលទ្ធផលក្នុងឆ្នាំ ជារង្វាស់បរិមាណ គុណភាព និង ពេលវេលានៃទំនិញ ឬ សេវាដែលបានបង្កើត ។

**ឧទាហរណ៍នៃសូចនាករលទ្ធផលក្នុងឆ្នាំ មានលក្ខណៈ ដូចខាងក្រោម ៖**

- ចំនួនសិស្សទទួលបានការបង្រៀន ឬ បណ្តុះបណ្តាលតាមស្តង់ដារ
- ចំនួនសាលារៀនដែលត្រូវសាងសង់ទៅតាមស្តង់ដារ និង គុណភាពនៃការសាងសង់
- ចំនួនអ្នកជំងឺដែលទទួលបានការព្យាបាលតាមស្តង់ដារសុខាភិបាល
- ចំនួនមនុស្សដែលទទួលបានការចាក់ថ្នាំបង្ការត្រឹមត្រូវ ។
- ទំហំផ្ទៃដីដាំដុះប្រើប្រាស់ប្រព័ន្ធស្រោចស្រព

ជារួម សូចនាករប្រើប្រាស់សម្រាប់វាស់វឌ្ឍនភាពនៃគោលដៅ និង គោលបំណងដែលសម្រេចបាន ។ ហេតុនេះ សូចនាករមានសារសំខាន់ណាស់ សម្រាប់ឆ្លុះបញ្ចាំងពីកម្រិតជោគជ័យនៃការអនុវត្តថវិកាកម្មវិធី ។

ដូច្នេះ ការកំណត់សូចនាករត្រូវពិចារណាដោយប្រុងប្រយ័ត្នទៅលើលក្ខណៈសម្បត្តិមួយចំនួន ដូចខាងក្រោម ៖

**១. សំខាន់ និង មានប្រយោជន៍ (Important, Relevant, and Useful)**

សូចនាករត្រូវវាស់វែងពីខ្លឹមសារសំខាន់នៃគោលបំណង ។ ឧទាហរណ៍ ចំពោះគោលបំណងនៃការបង្កើនផលិតកម្មកសិកម្មជាការងាយស្រួល យើងអាចយកការនាំចេញផលិតផលកសិកម្ម មកធ្វើជាសូចនាករបាន ។ ប៉ុន្តែអ្វីដែលសំខាន់ និង មានប្រយោជន៍សម្រាប់គោលបំណងនេះ គឺផលិតកម្មសរុបដែលឆ្លុះបញ្ចាំងពីខ្លឹមសារសំខាន់នៃគោលបំណង ។ ដូច្នេះ សូចនាករដែលជ្រើសរើសត្រូវអាចវាស់វែងបានផង និង ត្រូវឆ្លើយតបទៅនឹងខ្លឹមសារសំខាន់នៃគោលបំណងរបស់កម្មវិធីដែលត្រូវសម្រេចឲ្យបានផង ។

**២. មានភាពសមស្រប និង ទំនាក់ទំនងជាក់លាក់ (Attributable and Plausible)**

សូចនាករត្រូវកំណត់យ៉ាងណា ដើម្បីឲ្យអ្វីដែលត្រូវវាស់វែងនោះមានមូលហេតុសមស្រប និងជាក់លាក់ ហើយអាចភ្ជាប់ទំនាក់ទំនង និង ទទួលរងនូវឥទ្ធិពលពីចង្កោមសកម្មភាពដែលរួមចំណែកក្នុងការសម្រេចគោល-បំណងនៃអនុកម្មវិធី និង កម្មវិធី ។ ឧទាហរណ៍ បើកំណត់ថាកំណើននៃការនាំចេញផលិតផលកសិកម្ម ដែល

បណ្តាលមកពីការកែលម្អទៅតាមស្តង់ដារទីផ្សារអន្តរជាតិនោះ គឺមិនមានមូលហេតុគ្រប់គ្រាន់ និង ទំនាក់ទំនងជាក់លាក់នោះទេ ព្រោះថាកំណើននៃការនាំចេញផលិតផលកសិកម្ម អាចបណ្តាលមកពីកត្តាជាច្រើន ដូចជាការប្រែប្រួលថ្លៃ កិច្ចព្រមព្រៀងពាណិជ្ជកម្ម អត្រាប្តូរប្រាក់ ។ល។

**៣. មានគោលដៅច្បាស់លាស់ សាមញ្ញ និង ងាយយល់ (Targeted Simple Well Defined and Easily Understood)**

សូចនាករ ត្រូវមានគោលដៅច្បាស់លាស់ចំពោះបរិមាណ គុណភាព និង ពេលវេលា ។ ប្រសិនបើគ្មានកត្តាណាមួយក្នុងចំណោមកត្តាទាំងបីនេះសូចនាករមិនអាចធ្វើការវាស់វែង ថាតើយើងអាចសម្រេចបានលទ្ធផលចុងក្រោយឬទេ ។

ខាងក្រោមនេះ គឺជាឧទាហរណ៍សម្រាប់ជាមូលដ្ឋានក្នុងការកំណត់គោលដៅសូចនាករ ៖

**ឧទាហរណ៍ "ក"**

- **ទី ១ កំណត់សូចនាករ** : កំណើននៃការនាំចេញអង្ករ ។
- **ទី ២ កំណត់បរិមាណ** : កំណើននៃការនាំចេញអង្ករត្រូវសម្រេចឲ្យបាន ២០% ។
- **ទី ៣ កំណត់ពីគុណភាព** : កំណើននៃការនាំចេញអង្ករត្រូវសម្រេចឲ្យបាន ២០% នៅក្នុងកម្រិតថ្លៃថេរ ។
- **ទី ៤ កំណត់ក្របខ័ណ្ឌពេលវេលា** : កំណើននៃការនាំចេញអង្ករត្រូវសម្រេចឲ្យបាន ២០% ក្នុងរយៈពេលបីឆ្នាំខាងមុខ នៅក្នុងកម្រិតថ្លៃថេរ ។

**ឧទាហរណ៍ "ខ"**

- **ទី ១ កំណត់អំពីសូចនាករ** : កំណើននៃការបណ្តុះបណ្តាលគ្រូបឋមសិក្សា ។
- **ទី ២ កំណត់ពីបរិមាណ** : គ្រូបឋមសិក្សាត្រូវកើនឡើងចំនួន ១.៥០០ នាក់ ។
- **ទី ៣ កំណត់ពីគុណភាព** : ៨០% នៃគ្រូបឋមសិក្សាទទួលបានចំណាត់ថ្នាក់ល្អ សម្រាប់ការប្រឡងបញ្ចប់វគ្គបណ្តុះបណ្តាល ។
- **ទី ៤ កំណត់ក្របខ័ណ្ឌពេលវេលា** : គ្រូបឋមសិក្សានឹងកើនឡើងចំនួន ១.៥០០ នាក់ក្នុងរយៈពេល ៣ ឆ្នាំខាងមុខ ។

**៤. មានលក្ខណៈឯករាជ្យ (Independent)**

សូចនាករដែលវាស់សមិទ្ធផលនៃគោលបំណងនៅក្នុងកម្រិតមួយ មិនអាចយកមកធ្វើជាសូចនាករសម្រាប់វាស់សមិទ្ធផលនៃគោលបំណងនៅកម្រិតមួយទៀតបានទេ ព្រោះសូចនាករនៅក្នុងកម្រិតនីមួយៗ មានលក្ខណៈឯករាជ្យពីគ្នា ។ ឧទាហរណ៍ សូចនាករលទ្ធផលចុងក្រោយត្រូវមានលក្ខណៈឯករាជ្យពីសូចនាករលទ្ធផលក្នុងឆ្នាំ ហើយសូចនាករកម្មវិធីត្រូវមានលក្ខណៈឯករាជ្យពីសូចនាករអនុកម្មវិធី និងសូចនាករចង្កោម សកម្មភាព ។

ការភាន់ច្រឡំដែលយើងតែងសង្កេតឃើញក្នុងការអនុវត្ត គឺការវាស់វែងសមិទ្ធផលនៃលទ្ធផលចុង-ក្រោយ ដោយផ្អែកលើមធ្យោបាយដើម្បីសម្រេចបានលទ្ធផលចុងក្រោយ ។ ឧទាហរណ៍ ប្រសិនបើយើងធ្វើការ

វាស់វែងលទ្ធផលចុងក្រោយនៃភាពប្រសើរឡើងនៃការយល់ដឹងរបស់កសិករ ដោយប្រើប្រាស់សូចនាករកម្រិតទាប គឺ ចំនួនវគ្គបណ្តុះបណ្តាលបន្ថែមចំនួន ១០ វគ្គ ដែលត្រូវបានផ្តល់ដល់កសិករគឺជាការភាន់ច្រឡំ ព្រោះថា ចំនួនវគ្គបណ្តុះបណ្តាលបន្ថែមនេះ គឺជាលទ្ធផលក្នុងឆ្នាំនៃចង្កោមសកម្មភាព (មធ្យោបាយ) ។ ដោយឡែក ចំនួនកសិករដែលបានយកបច្ចេកវិទ្យាថ្មីទៅប្រើប្រាស់ ក្រោយការទទួលបានវគ្គបណ្តុះបណ្តាលនេះ ទើបជាសូចនាករដែលសមស្របសម្រាប់វាស់ភាពប្រសើរឡើងនៃការយល់ដឹងរបស់កសិករ ដែលនេះជាគោលបំណងនៃលទ្ធផលចុងក្រោយ ។

**៥. អាចទទួលយកបាន (Acceptable)**

សូចនាករ ត្រូវតែមានការឯកភាពពីគ្រប់ភាគីពាក់ព័ន្ធ ដែលចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងវាស់វែងការអនុវត្ត ។ សូចនាករ គួរតែត្រូវកំណត់ដោយគ្រប់ភាគីពាក់ព័ន្ធដែលជាអ្នកពិនិត្យតាមដាន និង វាយតម្លៃវឌ្ឍនភាពនៃការអនុវត្ត ហើយក៏ជាអ្នកកំណត់កត្តាជោគជ័យនៃកម្មវិធី ។ ឧទាហរណ៍ អ្នកគ្រប់គ្រងកម្មវិធី អាចគិតថា ទិន្នផលស្រូវក្នុងមួយហិកតា គឺជាសូចនាករមួយដ៏ល្អសម្រាប់វាស់ផលិតភាពស្រូវ ។ ប៉ុន្តែ អ្នកគ្រប់គ្រងអនុកម្មវិធី ឬ អ្នកពិនិត្យវាយតម្លៃកម្មវិធី អាចមានយោបល់ផ្សេងពីនេះ ។

**៦. ភាពស័ក្តិសិទ្ធិ (Effectiveness)**

ក្នុងការជ្រើសរើសសូចនាករ ត្រូវត្រួតពិនិត្យឡើងវិញពីហេតុផលនៃការកំណត់សូចនាករនីមួយៗ ដោយពិនិត្យវាយតម្លៃប្រភពទិន្នន័យដែលអាចរកបាន មានគុណភាព និង អាចជឿជាក់បាន ។

គួរមានការយកចិត្តទុកដាក់ខ្ពស់ចំពោះគុណភាពនៃសូចនាករ ដែលបានកំណត់នៅក្នុងថវិកាកម្មវិធី ។ ក្នុងន័យនេះ ទាមទារឲ្យមានការបណ្តុះបណ្តាលជាប្រចាំ អំពីវិធីសាស្ត្រនៃការជ្រើសរើសសូចនាករមកអនុវត្ត ។

នៅពេលដែលយើងបានកំណត់សូចនាករសមិទ្ធកម្មរួចហើយ ដើម្បីពិនិត្យឡើងវិញអំពីភាពសមស្របនិងអាចទទួលយកបាន គួរចោទជាសំណួរមួយចំនួន ដូចខាងក្រោម ៖

- តើសូចនាករ នឹងវាស់វែងពីខ្លឹមសារសំខាន់នៃគោលបំណងដែរឬទេ? ហើយមានកំណត់គោលដៅច្បាស់លាស់ដែលត្រូវសម្រេចដែរឬទេ?
- តើយើងមានការពិគ្រោះយោបល់ជាមួយគ្រប់ភាគីពាក់ព័ន្ធដែរឬទេ? ហើយមានការឯកភាពគ្នាទាំងស្រុងដែរឬទេ?
- តើសូចករនីមួយៗមានលក្ខណៈឯករាជ្យឬទេ? ហើយត្រូវបានកំណត់ត្រឹមត្រូវទៅតាមកម្រិតដែរឬទេ? ឧទាហរណ៍ : សូចនាករលទ្ធផលចុងក្រោយ គឺធ្វើការវាស់វែងលទ្ធផលចុងក្រោយ មិនមែនវាស់វែងចង្កោមសកម្មភាពទេ ។
- តើសូចនាករ មានគោលដៅសំខាន់ៗទាំង ៣ គឺបរិមាណ គុណភាព និង ពេលវេលាដែរឬទេ?

សំណួរខាងលើនេះ គ្រាន់តែជាមូលដ្ឋានសម្រាប់បញ្ជាក់ពីភាពសមស្របនៃសូចនាករសមិទ្ធកម្ម ហើយក៏អាចមានសំណួរច្រើនទៀត ដែលគួរយកមកពិចារណាបន្ថែមទៅក្នុងដំណើរការនៃការកំណត់សូចនាករសមិទ្ធកម្ម ។

## ២.៣ . ការគណនាតម្រូវការចំណាយសម្រាប់កម្មវិធី

ផ្នែកទី ២.២ និង ផ្នែកទី ២.៣ មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ព្រោះថាសូចនាករអាចសម្រេចទៅបាន អាស្រ័យលើកញ្ចប់ធនធានដែលមាន ។ ហេតុនេះក្រុមការងារថវិការបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្ត អាចជ្រើសរើសការគណនាតម្រូវការចំណាយសម្រាប់កម្មវិធី មុនការកំណត់សូចនាករក៏បាន ។ ក៏ប៉ុន្តែគោលការណ៍ណែនាំនេះ មានគោលបំណងផ្សារភ្ជាប់ផ្នែកទី ២.១ និង ផ្នែកទី ២.២ ដើម្បីងាយស្រួលក្នុងការកសាងកម្មវិធី ព្រោះនៅពេលកសាងថវិកាកម្មវិធី យើងត្រូវពិនិត្យសារចុះសារឡើង ដើម្បីធ្វើយ៉ាងណាឲ្យកសាងថវិកាកម្មវិធីដែលបានកំណត់នោះអាចអនុវត្តបាន នៅក្នុងកម្រិតកញ្ចប់ថវិកាប្រចាំឆ្នាំ និង ក្នុងកម្រិតកំណើននៃថវិកាសម្រាប់រយៈពេល ២ ឆ្នាំបន្ទាប់ ។

ផ្នែកនេះ ផ្តល់ការណែនាំពីការគណនាតម្រូវការចំណាយសម្រាប់កម្មវិធី ដែលរួមមានថ្លៃចំណាយសម្រាប់ធាតុចូលទាំងអស់ដែលត្រូវគណនាបន្ទាប់ពីធនធានដែលត្រូវការ សម្រាប់អនុវត្តសកម្មភាពការងារ ត្រូវបានកំណត់ ។

### ជំហានទី ៧ : វិធីសាស្ត្រក្នុងការគណនាតម្រូវការចំណាយសម្រាប់កម្មវិធី

**(ជំហានទី ៧ នេះ ផ្តល់នូវគំនិត និង វិធីគណនាតម្រូវការ ដើម្បីបំពេញព័ត៌មាននៅក្នុងតារាងឧបសម្ព័ន្ធទី ២.២, ២.៣ និង ២.៤ ដូចមានជូនភ្ជាប់មកជាមួយ)**

ក្នុងការគណនាតម្រូវការចំណាយសម្រាប់កម្មវិធី អាចមានជម្រើសពីរ គឺ (១) ការគណនាតម្រូវការចំណាយដោយផ្អែកលើធាតុចូល និង (២) ការគណនាតម្រូវការចំណាយដោយផ្អែកលើចង្កោមសកម្មភាព ។ ដូច្នេះ ក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្ត គួរជ្រើសរើសយកជម្រើសណាមួយសមស្របទៅតាមសមត្ថភាព និង លក្ខណៈពិសេសរបស់ខ្លួនក្នុងការគណនាតម្រូវការចំណាយសម្រាប់កម្មវិធី ។

ដើម្បីឲ្យកម្មវិធីមួយ មានធនធានគ្រប់គ្រាន់សម្រាប់អនុវត្ត និង អាចត្រួតពិនិត្យបានធៀបទៅនឹងកម្មវិធីផ្សេងៗទៀតនៅក្នុងក្រសួងតែមួយ តម្រូវឲ្យមានយន្តការសម្របសម្រួលមួយសម្រាប់កំណត់តម្រូវការចំណាយនៃកម្មវិធីទាំងនោះ ។ ទន្ទឹមនឹងនេះ វាក៏អាចឲ្យមានការផ្សារភ្ជាប់រវាងលទ្ធផលក្នុងឆ្នាំនៃកម្មវិធីទៅនឹងតម្រូវការចំណាយធាតុចូល ព្រមទាំងអាចវាយតម្លៃពីប្រសិទ្ធភាពនៃសមិទ្ធកម្មរបស់កម្មវិធី ។

គោលបំណងនៃការគណនាតម្រូវការចំណាយរបស់កម្មវិធី គឺ ៖

- កំណត់ពីតម្រូវការធាតុចូល (ធនធានដែលត្រូវប្រើប្រាស់សម្រាប់អនុវត្តចង្កោមសកម្មភាព)
- ប្រែក្លាយតម្រូវការធាតុចូលទាំងនេះទៅជាតម្រូវការទឹកប្រាក់ចំណាយជាក់ស្តែង
- វិភាជន៍តម្រូវការទឹកប្រាក់ចំណាយទាំងនេះទៅតាមចង្កោមសកម្មភាព ។

ជាទស្សនៈ ថ្លៃចំណាយទាំងអស់ត្រូវវិភាជន៍ទៅតាមកម្មវិធី ។ ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែង ធនធានមួយអាចត្រូវបានប្រើប្រាស់សម្រាប់កម្មវិធីលើសពីមួយ ដែលយើងគួរបែងចែកទៅតាមភាគរយនៃការប្រើប្រាស់សម្រាប់កម្មវិធីនីមួយៗ ។ ឧទាហរណ៍ : យានយន្តមួយត្រូវបានប្រើប្រាស់ ៧៥% សម្រាប់កម្មវិធីទី ១ ហើយ ២៥%

ទៀតសម្រាប់កម្មវិធីទី ២ ។ ដូច្នេះ ៧៥% នៃចំណាយក្នុងការប្រើប្រាស់យានយន្តនេះ ត្រូវបែងចែកទៅកម្មវិធីទី ១ និង ២៥% ត្រូវបែងចែកទៅកម្មវិធីទី ២ ។

ថ្លៃចំណាយគួរតែត្រូវបែងចែកទៅតាមកម្មវិធីប្រសិនបើអាចធ្វើបាន ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង ចំពោះប្រភេទចំណាយខ្លះ មានការលំបាកក្នុងការបែងចែកទៅតាមកម្មវិធី ។ ឧទាហរណ៍ : ដូចជាចំណាយលើបុគ្គលិកដែលក្នុងករណីខ្លះ បុគ្គលិកម្នាក់អាចមានការទទួលខុសត្រូវចំពោះចង្កោមសកម្មភាពច្រើន ឬ បម្រើឲ្យកម្មវិធីច្រើនជាងមួយ ។ ក្នុងករណីនេះ ដើម្បីអាចបំបែកចំណាយលើបុគ្គលិកម្នាក់ទៅតាមចង្កោមសកម្មភាព ឬ កម្មវិធីនីមួយៗបាន លុះត្រាតែអាចគណនាទៅតាមចំនួនម៉ោងដែលបុគ្គលនោះ ចំណាយជាក់ស្តែងទៅតាមចង្កោមសកម្មភាព ឬ កម្មវិធីនីមួយៗ ។ ការធ្វើដូចនេះ អាចចំណាយពេលច្រើន ហើយក៏ពុំទាន់ចាំបាច់សម្រាប់ការអនុវត្តថវិកាកម្មវិធីនៅក្នុងដំណាក់កាលបច្ចុប្បន្ន ។ ដូច្នេះប្រាក់បៀវត្សមិនគួរត្រូវធ្វើការបែងចែកទៅតាមចង្កោមសកម្មភាព ឬ កម្មវិធីនោះទេ ។

នៅក្នុងការប្រមូលព័ត៌មានស្តីពីថ្លៃចំណាយសម្រាប់ធាតុចូល ជាធម្មតាថ្លៃចំណាយអាចមានភាពខុសគ្នាទៅតាមតំបន់នីមួយៗ ឧទាហរណ៍ដូចជាថ្លៃដឹកជញ្ជូន និង ថ្លៃពលកម្មជាដើម ។ ប៉ុន្តែ ថ្លៃធាតុចូលមួយចំនួន យើងអាចកសាងឲ្យមានលក្ខណៈជាស្តង់ដារសម្រាប់ប្រើប្រាស់គ្រប់តំបន់ ។ ចំពោះថ្លៃធាតុចូលមួយចំនួនដែលមិនអាចរៀបចំឲ្យមានលក្ខណៈស្តង់ដារបាន អង្គភាពចំណាយត្រូវបង្កើតឲ្យមានទិន្នន័យថ្លៃ (Cost Database) ដើម្បីជាមូលដ្ឋានសម្រាប់គណនាថ្លៃចំណាយធាតុចូលទៅតាមតំបន់នីមួយៗ ឧទាហរណ៍ដូចជាថ្លៃចំណាយធាតុចូលមួយចំនួន សម្រាប់សាលារៀន ឬ ការិយាល័យសុខាភិបាលនៅថ្នាក់ស្រុក, ថ្នាក់ឃុំជាដើម ។

**ក. ការគណនាតម្រូវការចំណាយដោយផ្អែកលើធាតុចូល**

ការគណនាតម្រូវការចំណាយដោយផ្អែកលើធាតុចូល ចែកចេញជាពីរប្រភេទ គឺ ថ្លៃចំណាយធាតុចូលចរន្ត (Recurrent Inputs) និង ថ្លៃចំណាយធាតុចូលមូលធន (Capital Inputs) ។

ប្រភេទធាតុចូល និង ថ្លៃចំណាយ អាចបែងចែកដូចតទៅ ៖

**តារាងទី ៥ : តម្រូវការចំណាយដោយផ្អែកលើធាតុចូល**

| ថ្លៃចំណាយ | ប្រភេទធាតុចូល |
|---|---|
| ចរន្ត | ជាចំណាយដែលមាននៅក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា រួមមាន ជំពូក ៦០, ៦១, ៦២, ៦៣, ៦៤, និង ជំពូក ៦៥ ។ ឧទាហរណ៍ ដូចជា ទឹក អគ្គីសនី ការជួសជុល និង ថែទាំអគារ ប្រេងឥន្ធនៈ ការថែទាំយានយន្ត ការធានារ៉ាប់រងយានយន្ត សម្ភារៈ ការិយាល័យ (ក្រដាស ទឹកថ្នាំ ព្រីនធ័រ) ទូរស័ព្ទ ទូរសារ ការបណ្តុះបណ្តាល បុគ្គលិក ការប្រជុំ សិក្ខាសាលា បេសកកម្ម ជាដើម ។ល។ |
| មូលធន | ជាចំណាយដែលមាននៅក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា រួមមាន ជំពូក ២០ និង ២១ ។ ឧទាហរណ៍ ការវិនិយោគសាធារណៈ រួមមានដូចជា ការសាងសង់អគារ, ការកែលម្អអគារទ្រង់ទ្រាយធំ, ការកសាងប្រព័ន្ធធារាសាស្ត្រ, ផ្លូវថ្នល់ ។ ទិញសម្ភារៈមួយចំនួនផ្សេង |

| | |
|---|---|
| | ទៀត ក៏ជាប្រភេទមូលធនដែរ ដូចជាយានយន្ត គ្រឿងចក្រជាដើម ដែលមានកម្រិតកំណត់ទឹកប្រាក់ (Threshold) និង អាយុកាលនៃការប្រើប្រាស់ទៅតាមចំណាយបែបមូលធន។ |

ជារៀងរាល់ឆ្នាំ ក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្តទាំងអស់នឹងទទួលបានកញ្ចប់ថវិកាប្រចាំឆ្នាំ ហេតុនេះ អ្នកគ្រប់គ្រងថវិកាត្រូវចាត់ចែងកត់ត្រាចំណាយ ដើម្បីធានាថាក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្ត នឹងមិនមានការចំណាយលើសពីកញ្ចប់ថវិកាដែលមាន ។ ការកត់ត្រាគណនេយ្យ គឺជាចំណុចចាប់ផ្តើមដ៏សំខាន់មួយ ដើម្បីឈានទៅដល់ការកត់ត្រាថ្លៃធាតុចូលជាក់ស្តែងសម្រាប់កម្មវិធី ព្រោះបញ្ជីគណនេយ្យផ្តល់ព័ត៌មានដ៏មានតម្លៃ អំពីការចំណាយលើធាតុចូលនៃបណ្តាឆ្នាំកន្លងមក ។ ថ្លៃចំណាយធាតុចូលនៃបណ្តាឆ្នាំនីមួយៗ អាចប្រើប្រាស់ធ្វើជាមូលដ្ឋាន ដើម្បីព្យាករណ៍ថ្លៃចំណាយធាតុចូលដែលមានលក្ខណៈស្រដៀងគ្នា សម្រាប់បណ្តាឆ្នាំខាងមុខ ។ នៅពេលដែលយើងគ្មានព័ត៌មានអំពីថ្លៃចំណាយធាតុចូល ដោយសារតែថ្លៃចំណាយទាំងនោះ មិនបានចំណាយពីឆ្នាំកន្លងមក យើងអាចទទួលព័ត៌មានអំពីថ្លៃចំណាយធាតុចូលតាមរយៈតារាងថ្លៃ (Quotation) ពីបណ្តាអ្នកផ្គត់ផ្គង់ ។ ដូច្នេះ ការធ្វើបែបនេះ យើងអាចផ្សារភ្ជាប់ចំណាយលើធាតុចូលទៅនឹងចង្កោមសកម្មភាព ។ ឧទាហរណ៍ទី ៥ ខាងក្រោម គឺជាឧទាហរណ៍បង្ហាញពីថ្លៃចំណាយសម្រាប់ធាតុចូលនីមួយៗ ដែលបានបូកបញ្ចូលគ្នា ដើម្បីគណនាថ្លៃចំណាយសម្រាប់ចង្កោមសកម្មភាពនីមួយៗ ។

**ឧទាហរណ៍ទី ៥ : ការភ្ជាប់ថ្លៃចំណាយនៃធាតុចូលទៅនឹងចង្កោមសកម្មភាព**

| | ចង្កោមសកម្មភាព ១ : ការរៀបចំសេចក្តីព្រាងច្បាប់ | ចំណាយជាក់ស្តែង ឆ្នាំ ២០០៩ (លានរៀល) | សកម្មភាពដែលត្រូវអនុវត្ត ឆ្នាំ ២០១០ | តម្រូវការថវិកា ឆ្នាំ ២០១០ (លានរៀល) |
|---|---|---|---|---|
| ១.១. | ប្រជុំ (អ្នកចូលរួម ២០ នាក់ ដើម្បីព្រាងច្បាប់ចំនួន ៤ រៀងរាល់សប្តាហ៍។ ច្បាប់ នីមួយៗ ត្រូវការប្រជុំចំនួន ២ លើក ក្នុងមួយសប្តាហ៍ ដូច្នេះយើងមានកិច្ចប្រជុំ ចំនួន ៨ លើក ក្នុងមួយសប្តាហ៍<br>៥.០០០ រៀល x ២០ នាក់ x ៤១៦ លើក/ឆ្នាំ = ៤១.៦០០.០០០ រៀល | ៣១,២ | កិច្ចប្រជុំចំនួន៤១៦ លើកក្នុងមួយឆ្នាំ | ៤១,៦០ |
| ១.២. | សិក្ខាសាលាស្តីពីសេចក្តីព្រាងច្បាប់ : សេចក្តីព្រាងច្បាប់ចំនួន ៤ ។ សេចក្តីព្រាងនីមួយៗ ត្រូវការសិក្ខាសាលាចំនួន ១ ក្នុងមួយឆ្នាំ ។ ដូច្នេះ យើងមានចំនួនសិក្ខាសាលាសរុបចំនួន ៤ ក្នុងមួយឆ្នាំ (សិក្ខាសាលានីមួយៗ មានអ្នកចូលរួមចំនួន ១០០ នាក់ ហើយមានរយៈពេលបីថ្ងៃ)<br>• ជួលទីកន្លែងសម្រាប់សិក្ខាសាលា ៣ លាន x ៣ថ្ងៃ x ៤ លើក = ៣៦ លាន<br>• ភេសជ្ជៈ និង អាហារពេលព្រឹក ៤.០០០៛ x ១០០ x ៣ថ្ងៃ x ៤ = ៤.៨ លាន<br>• ភេសជ្ជៈនិងអាហារសម្រន់ល្ងាច ៣.០០០៛x១០០នាក់x៣ថ្ងៃx៤ = ៣.៦ ល<br>• អាហារថ្ងៃត្រង់ ១៥.០០០៛ x ១០០ នាក់ x ៣ថ្ងៃ x ៤ លើក = ១៨ លាន<br>• អាហារពេលល្ងាច ២៤.០០០៛ x១០០នាក់x ២ថ្ងៃ x៤ លើក = ១៩.២លាន<br>• ពិធីបិទសិក្ខាសាលា ៦០.០០០៛ x ១៣០ x ៤ = ៣១.២ លាន | | សិក្ខាសាលា ៤ ដងក្នុង ១ ឆ្នាំ | ១២៧,២៨ |

| | | | | |
|---|---|---|---|---|
| | • ការតុបតែង ៦០.០០០៛ x ៤ = ២.៤ លាន<br>• ទូរទស្សន៍ ៣២០.០០០៛ x ៤ = ១.២៨លាន<br>• ឯកសារ និង សម្ភារៈផ្សេងៗ ១៥.០០០៛ x ១០០ x ៤ = ៦.០ លាន<br>• ចំណាយផ្សេងៗ = ៤.៨ លាន<br>សរុប = = ១២៧.២៨ លាន | | | |
| ១.៣ | សម្ភារៈបរិក្ខារ<br>• ការថតចំលង = ៤១.០ លាន<br>• ដូលកុំព្យូទ័រ និង ព្រីនធ័រ (២) ៨.២លាន x ២ = ១៦.៤ លាន<br>សរុប = ៥៧.៤០ | | | ៥៧.៤០ |
| | សរុប (១.១ + ១.២ + ១.៣) | | | ២២៦,២៨ |

គួររំលឹកថា ចំពោះធាតុចូលដែលត្រូវប្រើប្រាស់សម្រាប់កម្មវិធីលើសពី ១ ត្រូវធ្វើការប៉ាន់ស្មានជា % (ភាគរយ) នូវធាតុចូល ដែលត្រូវប្រើប្រាស់សម្រាប់កម្មវិធីនីមួយៗ ។ ដូច្នេះ ថ្លៃចំណាយសម្រាប់ធាតុចូលដែលត្រូវប្រើប្រាស់សម្រាប់កម្មវិធីលើសពី ១ ត្រូវធ្វើការបែងចែកទៅតាមកម្មវិធីទាំងនោះ ដោយគិតជាភាគរយ ដូចដែលបានគូសបញ្ជាក់នៅក្នុងជំហានទី ៧ ខាងលើ ។

**១. ការគណនាតម្រូវការចំណាយដោយផ្អែកលើចង្កោមសកម្មភាព**

ខាងក្រោមនេះ គឺជាឧទាហរណ៍ដែលបង្ហាញពីវិធីសាស្រ្តក្នុងការកំណត់ថ្លៃចំណាយ ដោយផ្អែកលើចង្កោមសកម្មភាព ។ ការកំណត់ថ្លៃចំណាយដោយផ្អែកលើចង្កោមសកម្មភាព អាចធ្វើទៅបានដោយផ្អែកលើមូលដ្ឋាននៃបទពិសោធន៍ដែលបានអនុវត្តកន្លងមក ។

ឧទាហរណ៍ យើងបានកំណត់គោលដៅមួយ គឺបង្កើនសកម្មភាពការពារជំងឺគ្រុនចាញ់ ។ គិលានុប្បដ្ឋាយិកាម្នាក់នៅក្នុងស្រុក "ក" ត្រូវទទួលខុសត្រូវចំពោះមនុស្សចំនួន ១០.០០០ នាក់ ហើយជាគោលដៅគឺត្រូវបង្កើនចំនួនមនុស្សដែលទទួលបានការការពារជំងឺគ្រុនចាញ់ ដែលបច្ចុប្បន្នមានចំនួន ៤០% ឲ្យទៅដល់ ៥០% នៅឆ្នាំទីមួយ ៦០% នៅឆ្នាំទីពីរ និង ៧០% នៅឆ្នាំទីបី ។ ដូច្នេះ លទ្ធផលក្នុងឆ្នាំ និង លទ្ធផលចុងក្រោយនៃគោលដៅបង្កើនសកម្មភាពការពារជំងឺគ្រុនចាញ់នៅក្នុងស្រុក "ក" នេះគឺ ៖

- លទ្ធផលក្នុងឆ្នាំ គឺចំនួនមនុស្សដែលត្រូវបានការពារពីការកើតជំងឺគ្រុនចាញ់ ។
- លទ្ធផលចុងក្រោយ គឺ អ្នកកើតជំងឺគ្រុនចាញ់ត្រូវបានថយចុះ ។

នៅក្នុងការគណនាតម្រូវការចំណាយចង្កោមសកម្មភាព គួរពិចារណាទៅតាមជំហានបន្តបន្ទាប់ ដូចខាងក្រោម ៖

១. រក្សាទុកកម្រិតសេវាដែលមានបច្ចុប្បន្ន

២. បង្កើនសេវា ដើម្បីឆ្លើយតបទៅនឹងកំណើនចំនួនប្រជាជន

៣. គណនាកំណើននៃសេវាដែលត្រូវផ្តល់ ដើម្បីឆ្លើយតបទៅនឹងគោលដៅដែលបានកំណត់ ។

១១. ឧទាហរណ៍ទី ៦.១ : បង្ហាញពីស្ថានភាពបច្ចុប្បន្ន ។ ការផ្សព្វផ្សាយ និង ណែនាំអប់រំអំពីវិធីសាស្រ្តនៃការការពារជំងឺគ្រុនចាញ់មួយលើក ចាត់ទុកជាសកម្មភាពមួយ ។

| ឧទាហរណ៍ទី ៦.១ : ចំនួនប្រជាជនបច្ចុប្បន្នដែលគិលានុបដ្ឋាកយិកាបានធ្វើការផ្សព្វផ្សាយ និង អប់រំ | | | |
|---|---|---|---|
| ប្រភេទសកម្មភាព | ចំនួនប្រជាជន (បានចូលរួម) | ចំនួនសកម្មភាព (ចំនួនលើក) | ចំនួនប្រជាជនសរុប ដែលបានទទួលការផ្សព្វផ្សាយ និង អប់រំ |
| • ការពិភាក្សាតាមសហគមន៍ | ៥០ | ៤៥ | ២.២៥០ |
| • ការពិភាក្សាតាមសាលា | ៤៥ | ២៥ | ១.១២៥ |
| • ការពិភាក្សាផ្ទាល់ ជាមួយបុគ្គលម្នាក់ៗ | ៦២៥ | ៦២៥ | ៦២៥ |
| សរុប | | | ៤.០០០ |

**១២. ឧទាហរណ៍ទី ៦.២ : បង្ហាញពីការព្យាករណ៍កំណើនប្រជាជន**

| ឧទាហរណ៍ទី ៦.២ កំណើនប្រជាជន | | | | |
|---|---|---|---|---|
| កំណើនប្រជាជន | ចំនួនប្រជាជនបច្ចុប្បន្ន | ឆ្នាំទី ១ | ឆ្នាំទី ២ | ឆ្នាំទី ៣ |
| ៣% ក្នុងមួយឆ្នាំ | ១០.០០០ | ១០.៣០០ | ១០.៦០៩ | ១០.៩២៧ |

**១៣. ឧទាហរណ៍ទី ៦.៣ : បង្ហាញពីកំណើនតាមគោលដៅដែលបានកំណត់**

| ឧទាហរណ៍ទី ៦.៣ កំណើនតាមគោលដៅដែលបានកំណត់ដោយផ្អែកលើកំណើនប្រជាជន | | | | |
|---|---|---|---|---|
| | បច្ចុប្បន្ន | ឆ្នាំទី ១ | ឆ្នាំទី ២ | ឆ្នាំទី ៣ |
| ចំនួនប្រជាជនសរុបជាមួយនឹងកំណើន | ១០.០០០ | ១០.៣០០ | ១០.៦០៩ | ១០.៩២៧ |
| ភាគរយប្រជាជន ដែលត្រូវចូលរួមនៅក្នុងកម្មវិធី | ៤០% | ៥០% | ៦០% | ៧០% |
| គោលដៅកំណើន | ៤.០០០ | ៥.១៥០ | ៦.៣៦៥ | ៧.៦៤៩ |

មុខសញ្ញាចំណាយដែលត្រូវគណនា ដើម្បីអនុវត្តចង្កោមសកម្មភាពស្តីពីការបង្កើនការការពារជំងឺគ្រុនចាញ់ អាចចែកចេញជា ៣ ប្រភេទ ដូចខាងក្រោម ៖

១. ចំណាយរដ្ឋបាល : ជាចំណាយប្រតិបត្តិការរបស់ការិយាល័យសុខាភិបាលសាធារណៈ ដើម្បីអនុវត្តចង្កោមសកម្មភាពដល់ការបង្កើនការការពារជំងឺគ្រុនចាញ់ ។

២. ចំណាយសេវា : ជាចំណាយទៅលើសកម្មភាព ៣ ប្រភេទ គឺ ការពិភាក្សាជាមួយសហគមន៍ សាលារៀន និង ការពិគ្រោះយោបល់ផ្ទាល់ជាមួយបុគ្គលម្នាក់ៗ ដើម្បីអនុវត្តចង្កោមសកម្មភាពដល់ការបង្កើនការការពារជំងឺគ្រុនចាញ់ ។

៣. ចំណាយវិនិយោគ : ជាចំណាយលើទ្រព្យសម្ភារៈផ្សេងៗ ដែលស្ថិតក្នុងចំណាត់ថ្នាក់ចំណាយមូលធនសម្រាប់បម្រើឲ្យចង្កោមសកម្មភាពផល់ការបង្កើនការការពារជំងឺគ្រុនចាញ់ ។

១៤. ឧទាហរណ៍ទី ៦.៤ : បង្ហាញអំពីចំនួនសកម្មភាពដែលត្រូវអនុវត្ត ដោយផ្អែកលើចំនួនប្រជាជននៅមូលដ្ឋានដែលត្រូវចុះទៅផ្សព្វផ្សាយណែនាំ ។

| ឧទាហរណ៍ទី ៦.៤ ការកំណត់ចំនួនសកម្មភាព | | | | | | |
|---|---|---|---|---|---|---|
| ប្រភេទសកម្មភាព | ប្រជាជន | | | សកម្មភាពការងារ | | |
| | ឆ្នាំទី ១ | ឆ្នាំទី ២ | ឆ្នាំទី ៣ | ឆ្នាំទី ១ | ឆ្នាំទី ២ | ឆ្នាំទី ៣ |
| សេវា | | | | | | |
| • ការពិភាក្សាជាមួយសហគមន៍ | ២.៨៩៧ | ៣.៥៨០ | ៤.៣០៣ | ៥៨ | ៧២ | ៨៦ |
| • ការពិភាក្សានៅតាមសាលា | ១.៤៤៨ | ១.៧៩០ | ២.១៥១ | ៣២ | ៤០ | ៤៨ |
| • ការពិគ្រោះយោបល់ជាមួយ បុគ្គល | ៨០៥ | ៩៩៥ | ១.១៩៥ | ៨០៥ | ៩៩៥ | ១.១៩៥ |
| រដ្ឋបាល | | | | ១ | ១ | ១ |
| វិនិយោគ | | | | ១ | | |

វិធីសាស្ត្រនៃការកំណត់ចំនួនសកម្មភាពដែលបានប្រើនៅក្នុងការរៀបចំ ឧទាហរណ៍ទី ៦.៤ ខាងលើ មានដូចតទៅ ៖

ក្នុង ឧទាហរណ៍ទី ៦.៣ យកចំនួនប្រជាជនដែលត្រូវចូលរួមនៅក្នុងកម្មវិធីនៅក្នុងឆ្នាំទី ១ គឺ ៥.១៥០ គណនាកើនឡើងជាភាគរយនៃចំនួនប្រជាជនដែលត្រូវចូលរួមនៅក្នុងកម្មវិធីនៅក្នុងឆ្នាំទី ១ ដោយប្រៀបធៀបទៅនឹងឆ្នាំបច្ចុប្បន្ន គឺ ២៨,៧៥% ។

បង្កើនគ្រប់សេវាសកម្មភាពការងារទាំងអស់នៅក្នុងឧទាហរណ៍ទី ៦.១ (ការពិភាក្សាជាមួយសហគមន៍ ការពិភាក្សានៅតាមសាលា ការពិគ្រោះយោបល់ជាមួយបុគ្គល) ចំនួន ២៨,៧៥% ដើម្បីកំណត់ពីចំនួនសកម្មភាពថ្មី ។ ឧទាហរណ៍ :

សកម្មភាពចំនួន ៤៥ នៅក្នុងឧទាហរណ៍ទី ៦.១ កើនឡើង ២៨,៧៥% = ៥៨ សកម្មភាព

សកម្មភាពចំនួន ២៥ នៅក្នុងឧទាហរណ៍ទី ៦.១ កើនឡើង ២៨,៧៥% = ៣២ សកម្មភាព

សកម្មភាពចំនួន ៦២៥ នៅក្នុងឧទាហរណ៍ទី ៦.១ កើនឡើង ២៨,៧៥% = ៨០៥ សកម្មភាព

ការគណនាខាងលើ បានធ្វើឲ្យកើនឡើងនូវចំនួនសកម្មភាព ។ ដូច្នេះ បើយើងយកចំនួនប្រជាជនសរុបដែលបានទទួលការផ្សព្វផ្សាយ និង អប់រំ នៅក្នុងឧទាហរណ៍ទី ៦.១ គុណនឹងកំណើន ២៨,៧៥% យើងនឹងបានទទួលចំនួនប្រជាជនសរុបដែលត្រូវចូលរួមក្នុងកម្មវិធីការពារជំងឺគ្រុនចាញ់នៅឆ្នាំទី ១ ដូចខាង ក្រោម ៖

ចំនួនប្រជាជន ២.២៥០ (ឧទាហរណ៍ទី ៦.១) គុណកំណើន +២៨,៧៥% = ២.៨៩៧ នាក់

ចំនួនប្រជាជន ១.១២៥ (ឧទាហរណ៍ទី ៦.១) គុណកំណើន +២៨,៧៥% = ១.៤៤៨ នាក់

ចំនួនប្រជាជន ៦២៥ (ឧទាហរណ៍ទី ៦.១) គុណកំណើន +២៨,៧៥% = ៨០៥ នាក់

ចំនួនប្រជាជនសរុបដែលត្រូវចូលរួមកម្មវិធីការពារជំងឺគ្រុនចាញ់នៅឆ្នាំទី ១ = ២.៨៩៧ + ១.៤៤៨ + ៨០៥ = ៥.១៥០ នាក់

ដើម្បីគណនាចំនួនប្រជាជនចូលរួមកម្មវិធីការពារជំងឺគ្រុនចាញ់នៅឆ្នាំទី ២ និង ឆ្នាំទី ៣ យើងអាចប្រើវិធីសាស្ត្រដូចខាងលើ ដោយយកតួលេខឆ្នាំទី ១ ជាគោលក្នុងការគណនា ។

បន្ទាប់ពីបានកំណត់ចំនួនសកម្មភាពដូចនៅក្នុងឧទាហរណ៍ទី ៦.៤ រួចហើយ ជំហានបន្ទាប់គឺ ៖

១. កំណត់ធាតុចូល ដែលសកម្មភាពនីមួយៗត្រូវការ

២. ប៉ាន់ស្មានចំនួនធាតុចូលសម្រាប់សកម្មភាពនីមួយៗ

៣. គណនាថ្លៃចំណាយសរុបសម្រាប់សកម្មភាពនីមួយៗ

១៥. ឧទាហរណ៍ទី ៦.៥ : បង្ហាញពីវិធីសាស្ត្រ ក្នុងការកំណត់តម្រូវការធាតុចូល និង ការគណនាថ្លៃចំណាយសម្រាប់ធាតុចូល ។

| **ឧទាហរណ៍ទី ៦.៥ ការកំណត់ធាតុចូល និង គណនាថ្លៃចំណាយ សម្រាប់ធាតុចូល** | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | ធាតុចូល | | | | ធាតុចូល | | | | |
| ចំណាយរដ្ឋបាល | | | | | | | | | |
| | ប្រភេទ | បរិមាណ | ថ្លៃ | សរុប | ប្រភេទ | បរិមាណ | ថ្លៃ | សរុប | សរុបរួម |
| | ក្រដាស | ១០០ | ២ | ២០០ | ទឹក | | ២៨០ | ២៨០ | ៤៨០ |
| | ប៊ិច | ១០០ | ០,០៤ | ៤ | អគ្គីសនី | | ១.២០០ | ១.២០០ | ១.២០៤ |
| | | | | | ទូរស័ព្ទ | | ១.២០០ | ១.២០០ | ១.២០០ |
| សរុប | | | | ២០៤ | | | | ២.៦៨០ | ២.៨៨៤ |
| ចំណាយសេវា | | | | | | | | | |
| | ថ្លៃធ្វើដំណើរ | | | | សម្ភារៈការិយាល័យ | | | | |
| | ប្រភេទ | បរិមាណ | ថ្លៃ | សរុប | ប្រភេទ | បរិមាណ | ថ្លៃ | សរុប | សរុបរួម |
| ការពិភាក្សាជាមួយសហគមន៍ | ឥន្ធនៈ | ៥ | ៣,២ | ១៦,០ | Record cards | ១០០ | ១ | ១០០,០ | ១១៦,០ |
| ការពិភាក្សានៅតាមសាលា | ឥន្ធនៈ | ២ | ៣,២ | ៦,៤ | Recard cards | ៩០ | ១ | ៩០,០ | ៩៦,៤ |
| ការពិគ្រោះយោបល់ជាមួយបុគ្គល | ឥន្ធនៈ | ២ | ៣,២ | ៦,៤ | Recard cards | ៥ | ១ | ៥,០ | ១១,៤ |

| | ប្រភេទ | បរិមាណ | ថ្លៃ | សរុប | ប្រភេទ | បរិមាណ | ថ្លៃ | សរុប | សរុបរួម |
|---|---|---|---|---|---|---|---|---|---|
| ការពិភាក្សាជាមួយសហគមន៍ | 1st aid kit | ១ | ១០ | ១០ | | | | | ១០,០ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ការពិភាក្សានៅតាមសាលា | 1st aid kit | ១ | ១០ | ១០ | | | | | ១០,០ |
| ការពិគ្រោះយោបល់ជាមួយបុគ្គល | ថ្នាំ | ៥០ | ៣ | ១៥០ | | | | | ១៥០,០ |
| សេវាសរុប | | | | | | | | | ៣៩៣,៨ |
| ចំណាយវិនិយោគ | | | | | | | | | |
| | ប្រភេទ | បរិមាណ | ថ្លៃ | សរុប | ប្រភេទ | បរិមាណ | ថ្លៃ | សរុប | សរុបរួម |
| ចំណាយមូលធន | ឧបករណ៍ | ១ | ២០០ | ២០០ | | | | | ២០០ |

ក្រោយពីបានកំណត់ និង គណនាថ្លៃចំណាយសម្រាប់សកម្មភាពនីមួយៗ ដូចមាននៅក្នុងឧទាហរណ៍ទី ៦.៥ ខាងលើ ជំហានបន្ទាប់ត្រូវយកថ្លៃចំណាយសម្រាប់សកម្មភាពនីមួយៗនេះ ទៅគុណនឹងចំនួនសកម្មភាពសរុបដែលបានកំណត់សម្រាប់ការអនុវត្តនៅក្នុងឆ្នាំនីមួយៗ ដូចមានបង្ហាញនៅក្នុងឧទាហរណ៍ទី ៦.៤ ខាងលើ ។ ជាលទ្ធផល យើងនឹងបានថ្លៃចំណាយសម្រាប់ចង្កោមសកម្មភាពក្នុងរយៈពេល ៣ ឆ្នាំ ដូចបង្ហាញក្នុងឧទាហរណ៍ ទី ៦.៦ ខាងក្រោម ៖

១៦. ឧទាហរណ៍ទី ៦.៦ ខាងក្រោម បង្ហាញពីការគណនាថ្លៃចំណាយសម្រាប់ចង្កោមសកម្មភាពក្នុងរយៈពេល ៣ ឆ្នាំ

| ឧទាហរណ៍ទី ៦.៦ ថ្លៃចំណាយ សម្រាប់ចង្កោមសកម្មភាព ក្នុងរយៈពេល ៣ ឆ្នាំ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | ឆ្នាំទី ១ | | | ឆ្នាំទី ២ | | | ឆ្នាំទី ៣ | | |
| | សកម្មភាពការងារ | ថ្លៃ | សរុប | សកម្មភាពការងារ | ថ្លៃ | សរុប | សកម្មភាពការងារ | ថ្លៃ | សរុប |
| រដ្ឋបាល | ១ | ២.៨៨៤ | ២.៨៨៤ | ១ | ២.៨៨៤ | ២.៨៨៤ | ១ | ២.៨៨៤ | ២.៨៨៤ |
| សេវា | | | ១៤០.៦៤០ | | | ១៧៣.៩២១ | | | ២០៨.៩៧៧ |
| សហគមន៍ | ៥៨ | ១២៦,០ | ៧.៣០៨ | ៧២ | ១២៦,០ | ៩.០៧២ | ៨៦ | ១២៦,០ | ១០.៨៣៦ |
| សាលារៀន | ៣២ | ១០៦,៤ | ៣.៤០៥ | ៤០ | ១០៦,៤ | ៤.២៥៦ | ៤៨ | ១០៦,៤ | ៥.១០៧ |
| បុគ្គល | ៨០៥ | ១៦១,៤ | ១២៩.៩២៧ | ៩៩៥ | ១៦១,៤ | ១៦០.៥៩៣ | ១.១៩៦ | ១៦១,៤ | ១៩៣.០៣៤ |
| វិនិយោគ | ១ | ២០០ | ២០០ | | | | | | |
| សរុប | | | ១៤៣.៧២៤ | | | ១៧៦.៨០៥ | | | ២១១.៨៦១ |

ថ្លៃចំណាយខាងលើនេះ គឺគណនាទៅតាមតម្លៃជាក់ស្តែងនៅលើទីផ្សារ ដោយមិនគិតពីអតិផរណាដែលអាចកើតមានឡើងនោះទេ ។ កត្តាអតិផរណានឹងធ្វើការគិតគូរដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

នៅពេលដែលយើងបានកំណត់ពីថ្លៃចំណាយរួចហើយ ចំណុចដែលសំខាន់នោះ គឺត្រូវកំណត់ថាតើថ្លៃទាំងនោះមានភាពសមស្របឬទេ ដោយធ្វើការចោទសួរជាសំណួរ ដូចខាងក្រោម ៖

- តើធាតុចូល និង ថ្លៃធាតុចូលដែលបានកំណត់មានលក្ខណៈត្រឹមត្រូវឬទេធៀបនឹងធាតុចូល និង ថ្លៃធាតុចូលផ្សេងៗទៀត?
- តើការកំណត់អំពីប្រភេទ និង បរិមាណនៃធាតុចូលបានត្រឹមត្រូវដែរឬទេ?
- តើមានសកម្មភាព ឬ ធាតុចូលដែលត្រួតគ្នាដែរឬទេ?
- តើមានជម្រើស ដើម្បីកាត់បន្ថយថ្លៃសម្រាប់ចង្កោមសកម្មភាពដែរឬទេ?
- តើយើងត្រូវការធាតុចូលទាំងអស់ដែលបានកំណត់ឬទេ? ឬមួយយើងអាចកាត់បន្ថយធាតុចូលមួយចំនួនហើយ នៅតែអាចសម្រេចបានលទ្ធផលក្នុងឆ្នាំដូចគ្នា?
- តើមានតុល្យភាពដែរឬទេ រវាងចំណាយដែលបានគ្រោងសម្រាប់ដំណើរការរដ្ឋបាល និង ការផ្តល់សេវា?

សំណួរមួយចំនួនខាងលើនេះ គ្រាន់តែជាមូលដ្ឋានសម្រាប់បញ្ជាក់ពីភាពសមស្របនៃការកំណត់ធាតុចូល និង ការគណនាថ្លៃចំណាយ ហើយក៏អាចមានសំណួរច្រើនទៀតដែលគួរយកមកពិចារណាបន្ថែមនៅក្នុងដំណើរការនៃការកំណត់ធាតុចូល និង ការគណនាថ្លៃចំណាយឲ្យមានភាពសមស្រប ។

## ២.៤. ការត្រួតពិនិត្យឡើងវិញលើថវិកាកម្មវិធីដែលបានកសាង

នៅពេលរចនាសម្ព័ន្ធកម្មវិធី និង អនុកម្មវិធី គោលបំណង គោលដៅ លទ្ធផលចុងក្រោយ លទ្ធផលក្នុងឆ្នាំ និង ចង្កោមសកម្មភាព ត្រូវបានកំណត់ទន្ទឹមនឹងថ្លៃចំណាយសម្រាប់អនុវត្តចង្កោមសកម្មភាព ត្រូវបានគណនាហើយសូចនាករសមិទ្ធកម្មដែលបានជ្រើសរើស យើងត្រូវធ្វើការពិនិត្យឡើងវិញចំពោះតក្កនៃខ្សែចង្វាក់លទ្ធផល (Logic of the Results Chain) ។ គោលបំណងនៃការពិនិត្យឡើងវិញ គឺដើម្បីធានាថាលទ្ធផលចុងក្រោយនឹងសម្រេចបានគោលបំណង ហើយលទ្ធផលក្នុងឆ្នាំនឹងសម្រេចបានលទ្ធផលចុងក្រោយ ។ ចង្កោមសកម្មភាពនឹងសម្រេចបានលទ្ធផលក្នុងឆ្នាំ ហើយធាតុចូលអាចឲ្យយើងអនុវត្តចង្កោមសកម្មភាពបាន ។

តារាងទី ៦ ខាងក្រោម នឹងផ្តល់ជាគំនិតបន្ថែមអំពីតក្កនៃការកសាងសូចនាករលទ្ធផលក្នុងឆ្នាំ ក៏ដូចជាលទ្ធផលចុងក្រោយ ។

| ពាក្យ | អត្ថន័យ | ឧទាហរណ៍ | សូចនាករ |
|---|---|---|---|
| គោលបំណង (Objective) | ហេតុផលដែលត្រូវបង្កើតលទ្ធផលក្នុងឆ្នាំ និង លទ្ធផលចុងក្រោយ | ការកែលម្អគុណភាព និង ប្រសិទ្ធភាពនៃការអប់រំនៅ បឋមសិក្សា | អត្រាអ្នកចេះអានកើនឡើង |
| លទ្ធផលចុងក្រោយ (Outcome) | លទ្ធផលដែលទទួលបានពីការសម្រេចបាននូវលទ្ធផលក្នុងឆ្នាំ | សិស្សទទួលបានការអប់រំប្រសើរជាងមុន | ចំនួនគ្រូបង្រៀនបឋមសិក្សាដែលបានយកការបណ្តុះបណ្តាលតាមស្តង់ដារមកអនុវត្ត |
| លទ្ធផលក្នុងឆ្នាំ | ទំនិញ និង សេវា ដែលបាន | សមត្ថភាព និង គរុកោ- | ចំនួនវគ្គបណ្តុះបណ្តាលដែលបានផ្តល់ |

| | | | |
|---|---|---|---|
| (Output) | មកពីការអនុវត្តចង្កោមសកម្មភាព | សល្យគ្រូត្រូវបានបង្កើន | |
| ចង្កោមសកម្មភាពការងារ (Activities) | ជាក្រុមនៃសកម្មភាពដែលមានគោលបំណងច្បាស់លាស់ នៅក្នុងអនុកម្មវិធី | វគ្គបណ្តុះបណ្តាលគ្រូបង្រៀន ឬ ការកសាងសាលារៀន | អត្រាវឌ្ឍនភាពនៃការអនុវត្តផែនការការងារ ដោយប្រើប្រាស់ធាតុចូលប្រកបដោយប្រសិទ្ធភាព |
| ធាតុចូល | ធនធាន និង ថ្លៃ ដែលត្រូវការដើម្បីអនុវត្តចង្កោមសកម្មភាព | ដីធ្លី អគារ សម្ភារៈបរិក្ខារ សៀវភៅអាន | ធាតុចូលត្រូវបានផ្តល់ជូនតាមពេលវេលា មានបរិមាណ និង គុណភាពត្រឹមត្រូវស្របតាមថវិកាដែលមាន |

ការពិនិត្យបែបនេះ គឺមានសារសំខាន់ពីព្រោះបានផ្តល់នូវឱកាសដើម្បីសួរថា តើខ្សែចង្វាក់លទ្ធផលនៅក្នុងកម្មវិធី អាចជួយឲ្យយើងសម្រេចបានគោលបំណងកម្មវិធីដែរឬទេ? យើងត្រូវធ្វើការពិនិត្យឡើងវិញចំពោះសំណួរដែលត្រូវសួរ នៅដំណាក់កាលនីមួយៗក្នុងការរៀបចំថវិកាកម្មវិធី ដើម្បីធានាថាគ្រប់ជំហានដែលបានរៀបចំមានសង្គតិភាព និង សមស្រប ។

## ជំហានទី ៨ : វិធីសាស្ត្រក្នុងការត្រួតពិនិត្យឡើងវិញលើថវិកាកម្មវិធីដែលបានកសាង

**(ជំហានទី ៨ មានសារសំខាន់ ដើម្បីពិនិត្យឡើងវិញភាពសមស្រប និង តក្កភាពនៃខ្សែចង្វាក់លទ្ធផលដែលបានកសាងតារាងឧបសម្ព័ន្ធទី ២.១, ២.២, ២.៣ និង ២.៤)**

ក្របខ័ណ្ឌតក្ក (Log-Frame) ដែលមានក្នុងតារាងទី ៧ ខាងក្រោម នឹងផ្តល់នូវមូលដ្ឋានសម្រាប់ត្រួតពិនិត្យឡើងវិញពីទំនាក់ទំនងរវាងធាតុចូល ចង្កោមសកម្មភាព លទ្ធផលក្នុងឆ្នាំ លទ្ធផលចុងក្រោយ និង គោលបំណងនៃកម្មវិធី ។

តារាងទី ៧

| ចំណងជើងនៃកម្មវិធី | | កាលបរិច្ឆេទនៃការត្រួតពិនិត្យឡើងវិញ | |
|---|---|---|---|
| ការពិពណ៌នាពីកម្មវិធី | | | |
| របនាសម្ព័ន្ធ | សូចនាករសមិទ្ធកម្ម | សូចនាករដើម្បីបញ្ជាក់ | ហានិភ័យ |
| គោលបំណងនៃកម្មវិធី | | | |
| តើកម្មវិធីនឹងរួមចំណែកសម្រេចគោលបំណងគោលនយោបាយណាមួយ? | | | តើមានលក្ខខណ្ឌខាងក្រៅចាំបាច់អ្វីខ្លះដើម្បីសម្រេចបានគោលបំណងកម្មវិធី? តើយើងអាចកាត់បន្ថយហានិភ័យដែលមានដែរឬទេ? តាមរបៀបណា? |
| លទ្ធផលចុងក្រោយ | | | |
| តើអ្វីទៅជាគោលនយោបាយ ដែលរំពឹងទុក? | តើលទ្ធផលជាបរិមាណ និង គុណភាពបែបណាខ្លះដែលត្រូវសម្រេចជា | តើមានតួលេខអ្វីសម្រាប់វាស់វែងពីសូចនាករ? តើតួលេខទាំងនេះអាចរ | តើមានលក្ខខណ្ឌខាងក្រៅដែលចាំបាច់អ្វីខ្លះ ដើម្បី សម្រេចបានលទ្ធផលចុងក្រោយ? |

| | | | |
|---|---|---|---|
| | លទ្ធផលចុងក្រោយ? | ក បានឬទេ? | តើយើង អាចកាត់បន្ថយហានិភ័យដែលមានបានដែរឬទេ? តាមរបៀបណា? |
| លទ្ធផលក្នុងឆ្នាំ | | | |
| តើអ្វីខ្លះ ដែលត្រូវបង្កើតសម្រេចលទ្ធលផចុងក្រោយ | តើលទ្ធផលជាបរិមាណ និង គុណភាពបែបណាខ្លះដែលត្រូវសម្រេចជាលទ្ធផលក្នុងឆ្នាំ? ហើយត្រូវបង្កើតនៅពេលណា? | តើមានតួលេខអ្វីសម្រាប់វាស់វែងពីសូចនាករ? តើតួលេខទាំងនេះអាចរក បានឬទេ? | តើកត្តាអ្វីខ្លះដែលរារាំងមិនឲ្យលទ្ធផលក្នុងឆ្នាំអាចសម្រេចបាន? តើយើងអាចកាត់បន្ថយហានិភ័យ ដែលមានបានដែរឬទេ? តាមរបៀបណា? |
| ចង្កោមសកម្មភាព | | | |
| តើមានចង្កោមសកម្មភាពអ្វីខ្លះដែលត្រូវអនុវត្តដើម្បីទទួលបានលទ្ធផលក្នុងឆ្នាំ? | តើចង្កោមសកម្មភាពណាខ្លះ ដែលត្រូវអនុវត្ត? នៅពេលណា?ដោយនរណា? | តើមានប្រភពតួលេខអ្វីសម្រាប់វាស់សូចនាករ? តើតួលេខទាំងនោះ អាចរកបានឬទេ? | តើកត្តាអ្វីខ្លះដែលរារាំងមិនឲ្យចង្កោមសកម្មភាពអាចសម្រេចបាន? តើយើងអាចកាត់បន្ថយហានិភ័យដែលមានបានដែរឬទេ? តាមរបៀបណា? |
| ធាតុចូល | | | |
| តើមានធនធានហិរញ្ញវត្ថុ និង ធនធានអ្វីទៀត ដែលយើងត្រូវការ ដើម្បីអនុវត្តចង្កោមសកម្មភាព? | តើធនធាន ត្រូវបានផ្គត់ផ្គង់ទាន់ពេលវេលាដែរឬទេ? តើធនធាននោះមានបរិមាណ និង គុណភាពត្រឹមត្រូវដែរឬទេ? | តើមានប្រភពតួលេខអ្វីសម្រាប់វាស់សូចនាករ? តើតួលេខទាំងនោះអាចរក បានឬទេ? | តើមានកត្តាអ្វីដែលបង្កការយឺតយ៉ាវដល់ការផ្គត់ផ្គង់ធាតុចូល? តើយើងអាចកាត់បន្ថយហានិភ័យដែលមានបានដែរឬទេ? តាមរបៀបណា? |

បន្ទាប់ពីបានបញ្ចប់ជំហានទី ១ រហូតដល់ជំហានទី ៨ ក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្ត ត្រូវផ្ញើជូនក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) នូវគំរោងផែនការថវិកាកម្មវិធីដើម្បីពិនិត្យ និង អនុម័តទៅតាមពេលវេលាកំណត់ ដែលមានចែងនៅក្នុងសារាចរណែនាំស្តីពីការរៀបចំថវិកាប្រចាំឆ្នាំ ។ ក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្ត មានកាតព្វកិច្ចពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធកម្មវិធីពីមួយឆ្នាំទៅមួយឆ្នាំដើម្បីធានាថាថវិកាកម្មវិធីដែលបានកសាងអាចសម្រេចយុទ្ធសាស្ត្រអាទិភាព ក៏ដូចជាគោលនយោបាយរបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្ត ។ ក្នុងករណីមានការចាំបាច់បន្ថែម ឬ បន្ថយកម្មវិធី ឬ អនុកម្មវិធី ត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ៣. ការពិនិត្យតាមដាន វាយតម្លៃការអនុវត្ត និង ធ្វើរបាយការណ៍

ផ្នែកនេះ ផ្តល់នូវការណែនាំស្តីពីការពិនិត្យតាមដាន វាយតម្លៃការអនុវត្ត និង ធ្វើរបាយការណ៍ថវិកាកម្មវិធី ។

## ជំហានទី ៩ : វិធីសាស្ត្រក្នុងការឆ្លើយតបទៅនឹងតម្រូវការសម្រាប់ពិនិត្យតាមដាន វាយតម្លៃ និង ធ្វើរបាយការណ៍

**(ជំហានទី ៩ នេះ ផ្តល់នូវសេចក្តីពន្យល់ ដើម្បីបំពេញព័ត៌មានក្នុងតារាងឧបសម្ព័ន្ធទី ៣.១ ដល់៣.៥)**

ក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្ត ត្រូវបង្កើតយន្តការ និង នីតិវិធីសម្រាប់ពិនិត្យតាមដាន វាយតម្លៃ និង ធ្វើរបាយការណ៍របស់ខ្លួនដើម្បីបញ្ជូនមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ដើម្បីសម្រួលដល់ការរៀបចំរបាយការណ៍ "ឧបសម្ព័ន្ធទី ៣" ផ្តល់ជាគំរូទម្រង់របាយការណ៍ និង របៀបនៃការបំពេញ ។

របាយការណ៍ចែកជាពីរប្រភេទ : ទី ១ របាយការណ៍ហិរញ្ញវត្ថុ និង ទី ២ របាយការណ៍វឌ្ឍនភាព ដែលឆ្លុះបញ្ចាំងពីសូចនាករសមិទ្ធកម្មសម្រាប់កម្មវិធី ។

**របាយការណ៍ហិរញ្ញវត្ថុ** : ទម្រង់នៃរបាយការណ៍នេះ ផ្តល់ជូននៅក្នុងតារាងឧបសម្ព័ន្ធទី ៣.១ ឧបសម្ព័ន្ធទី ៣.២ និង ឧបសម្ព័ន្ធទី ៣.៤ ។ ក្រសួងស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្ត ត្រូវផ្ញើរបាយការណ៍មកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ/មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគាររាជធានី ខេត្ត តាមនីតិវិធី ដូចតទៅ ៖

**ក. សម្រាប់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្ត**

១. ជារៀងរាល់ខែ ត្រូវរៀបចំរបាយការណ៍ស្តីពីការអនុវត្តថវិកា ដោយញែកទៅតាមកម្មវិធី ជំពូក គណនី អនុគណនី ។

២. របាយការណ៍ ត្រូវបញ្ជូនទៅអគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគាររាជធានីខេត្ត នាយកដ្ឋានថវិកា នាយកដ្ឋានហិរញ្ញកិច្ច/មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរាជធានី ខេត្ត ឲ្យបានមុនថ្ងៃទី ២៥ នៃខែនីមួយៗ ។

**ខ. សម្រាប់អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគាររាជធានី ខេត្ត**

១. រៀងរាល់ខែ រតនាគាររាជធានី ខេត្ត ត្រូវបញ្ជូនតុល្យភាពគណនី របាយការណ៍ចំណាយថវិកា ដោយញែកថវិកាកម្មវិធី ថវិកាមិនមែនកម្មវិធី និង របាយការណ៍ចំណូលថវិកាមកអគ្គនាយកដ្ឋានរតនាគារជាតិ ។

២. អគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវផ្តល់របាយការណ៍ចំណាយថវិកាកម្មវិធី ថវិកាមិនមែនកម្មវិធី និង តារាងតុល្យភាពគណនីប្រចាំខែដល់នាយកដ្ឋានថវិកា ។

**របាយការណ៍វឌ្ឍនភាព** : ទម្រង់នៃរបាយការណ៍នេះ ផ្តល់ជូននៅក្នុងតារាងឧបសម្ព័ន្ធទី ៣.៣ និង ឧបសម្ព័ន្ធទី ៣.៥ ។ ក្រសួងស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្ត ត្រូវផ្ញើរបាយការណ៍មកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ/មន្ទីរសេដ្ឋកិច្ចរាជធានី ខេត្ត តាមនីតិវិធី ដូចតទៅ ៖

១. ជារៀងរាល់ត្រីមាស ត្រូវផ្ញើរបាយការណ៍ដែលបង្ហាញពីវឌ្ឍនភាពនៃថវិកាកម្មវិធី ដោយប្រៀបធៀបទៅនឹងសូចនាករសមិទ្ធកម្មសម្រាប់កម្មវិធី មកនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

២. ត្រូវធ្វើការពន្យល់លំអិតពីភាពខុសគ្នារវាងវឌ្ឍនភាពដែលបានគ្រោង និង វឌ្ឍនភាពជាក់ស្តែង ដោយប្រៀបធៀបទៅនឹងសូចនាករសមិទ្ធកម្មសម្រាប់កម្មវិធី ។

៣. ចំពោះកម្មវិធី ដែលមិនមានវឌ្ឍនភាពតាមការគ្រោងទុក ក្រសួង ស្ថាប័ន និង មន្ទីរជំនាញ រាជធានី ខេត្ត ត្រូវផ្តល់ព័ត៌មានអំពីវិធានការដែលត្រូវប្រកាន់យកដើម្បីទទួលបានវឌ្ឍនភាព ដូចដែលបានគ្រោងទុក ។

ទន្ទឹមនេះ ឧបសម្ព័ន្ធទី ២ និង ឧបសម្ព័ន្ធទី ៣ ក៏បានរៀបរាប់លំអិតផងដែរ អំពីរបៀបបំពេញទម្រង់របាយការណ៍ ។ ហេតុនេះ ពុំមានការចាំបាច់ដើម្បីធ្វើការណែនាំបន្ថែមទៀតឡើយ ។

ជាសរុប ការណែនាំពីជំហានទី ១ ដល់ជំហានទី ៩ បង្ហាញពីតម្រូវការចាំបាច់ និង គ្រប់គ្រាន់ ដើម្បីកសាងគំរោងថវិកាកម្មវិធី និង ការអនុវត្តថវិកាកម្មវិធី ។

# ៤. ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី ១ : ការកំណត់ធាតុចូល ចង្កោមសកម្មភាព លទ្ធផលក្នុងឆ្នាំ និង លទ្ធផលចុងក្រោយ

ឧទាហរណ៍នៃការកំណត់ អ្វីទៅជាធាតុចូល (Input) ឬចង្កោមសកម្មភាព (Activity) ឬ លទ្ធផលក្នុងឆ្នាំ (Output) ឬលទ្ធផលចុងក្រោយ (Outcome)

| ខ្លឹមសារ | ការកំណត់ |
|---|---|
| ការប៉ាន់ស្មានថវិកា<br>Budget estimates | សកម្មភាព<br>Activity |
| អត្រាសិស្សដែលប្រឡងជាប់កើនឡើង<br>Pupil pass rate in examinations increases | Outcome<br>លទ្ធផលចុងក្រោយ |
